# ១

## លក្ខណៈបញ្ចូលប្រទេសដទៃ ជាឧបសម្ព័ន្ធរបស់យួន

– <u>អំពើឈ្លានពាន</u> : ការពង្រីកទឹកដីយកមកធ្វើជាអនានិគម និងការបញ្ចូលជាឧបសម្ព័ន្ធ បានប្រព្រឹត្តទៅដោយប្រទេសយួន ពីអតីតកាល ។

អំពើឈ្លានពាន និងការបញ្ចូលទឹកដីប្រទេសដទៃ ជាឧបសម្ព័ន្ធបានប្រព្រឹត្តរួចទៅហើយ ដោយយួនពីអតីតកាលក៏ដូចជានៅពេលបច្ចុប្បន្នកាលនេះដែរ ដែលអាចឲ្យលោកអ្នកសង្កេតការពិនិត្យឃើញច្បាស់អំពីចរិតពិតប្រាកដរបស់យួន និងប្រទេសយួនគឺជាលក្ខណៈឈ្លានពាន លក្ខណៈបញ្ចូលជាឧបសម្ព័ន្ធ ហើយលេបយកទឹកដីប្រទេសឯទៀតៗ ។

ការបញ្ចូលជាឧបសម្ព័ន្ធនៃប្រទេសចម្ប៉ា និងកម្ពុជាក្រោម ធ្វើជារបស់យួន ដែលមានជាភ័ស្តុតាងស្រាប់ ។

ក)-ប្រទេសចម្ប៉ា :

ប្រទេសចម្ប៉ា បានកកើតឡើងនៅ សតវត្សទី២ ក្នុងយុគ្គសម័យនគរភ្នំរបស់កម្ពុជា ។

ទឹកដីរបស់ចម្ប៉ា គឺជាផ្នែកកណ្តាលនៃប្រទេសយួនសព្វថ្ងៃនេះ ។ ដែលគេហៅប្រជាជននេះថា "ចាម" ។

ប្រទេសចម្ប៉ា មានអារ្យធម៌ត្រចះត្រចង់ ជាយូរអង្វែងនៅអាស៊ីប៉ែកអគ្នេយ៍ ដូចមានប្រាសាទ មីសុន ជាភ័ស្តុតាងស្រាប់ ។

ពួកយួនវាបានប្រព្រឹត្ត អំពើឈ្លានពានជានិរន្ត លុះបញ្ចូលប្រទេសចម្ប៉ាជាឧបសម្ព័ន្ធពេញលេញរបស់វាតែម្តង ។

- នៅឆ្នាំ១៤៧១ យួនវាបានវាយលុកចូលរដ្ឋធានីចម្ប៉ា ឈ្មោះវិជ័យ (Vijaya) ហើយវាដាក់ឈ្មោះប្រទេសចម្ប៉ាជា បិញ ឌិញ (Binh Dinh) ជំនួសទៅវិញ ។

ចាប់តាំងពីពេលនោះ មកប្រទេសចម្ប៉ាបានធ្លាក់ចុះឱនភាព ហើយបាត់បង់ទឹកដីបន្តិចម្តងៗ ព្រមទាំងប្រជាជាតិទាំងមូលថែមទៀត ។

ហេតុនេះ, បន្ទមកពួកយួនក៏បានលេបយកទឹកដីរបស់ប្រទេសចម្ប៉ាទាំងមូល ហើយបញ្ចូលប្រជាពលរដ្ឋចាមមកនៅភាគខាងត្បូងនៃរដ្ឋធានី វិជ័យ (Vijaya) ។

- នៅឆ្នាំ១៦១១ ពួកយួនវាបានបញ្ចូលតំបន់ ភូយេន (Phu Yen) ទៅប៉ែកខាងត្បូងនៃ គីញ៉ុង (Qui Ngon) ទៀត ។

- នៅឆ្នាំ១៦៥៣ ពួកយួនវាបានបញ្ចូលតំបន់ ខាញ់ ហ្វា (Khanh Hoa) ឬជាភាសាចាមហៅថា គុន្ធថារ៉ា (Kaunthara) នៅកន្ទែងជិតខេត្ត ញ៉ា ត្រាង (Nha Trang) និងខេត្តផាន់រ៉ាង (Phan Rang) ថែមទៀត ។

- នៅឆ្នាំ១៦៩៣ យួនវាបានលេបត្បៀក ពេញលក្ខណៈរបស់ប្រទេសចម្ប៉ា ដោយបញ្ចូលតំបន់ ផាន់ ធៀត (Phan Thiet) ជាចុងក្រោយបង្អស់ ។

ជាតិសាសន៍ចាមបានត្រូវយួនវាដេញសម្លាប់ រង្គាលគ្មានបង្អង់ ។ ទន្ទឹមនិងការទន្ទ្រានរាតត្បាតនៃប្រទេសចម្ប៉ាមក ពួកយួនវាក៏បានកំរាមកំហែង បង្ខំឲ្យប្រទេសលាវ ចូលក្នុងអាណានិគមរបស់យួនទៀត ។

កាលណាប្រទេសចម្ប៉ា បានត្រូវត្របាក់លេបរួចហើយ ពួកយួនវាបានបន្ត ការវៀតទីនិយមរបស់វា ឆ្ពោះទៅកម្ពុជាក្រោមតទៅទៀត ។

១)- កម្ពុជាក្រោម :

គឺជាផ្នែកទឹកដីខ្មែរ នៅប្រទេសយួនខាងត្បូងសព្វថ្ងៃនេះ

ដែលមានតំបន់ខាងទិសបស្ចឹម នៃទន្លេ ដូណៃ (Donai) និង ដីសណ្តរ នៃទន្លេមេគង្គ ។ ដែលបារាំងសែសគេហៅថា ៖ កូសាំងស៊ីន (Cochinchine) ។

ទឹកដីនេះជាផ្នែកមួយយ៉ាងសំខាន់ក្នុងកម្ពុជាក្រោម តាំងពីជាង ២០០០ ឆ្នាំមកហើយ ។ ពួកយួនវាបានចាប់ផ្តើមបំពាន ទៅលើកម្មសិទ្ធទឹកដីនេះ នៅដើមសតវត្សទី ១៧ ។

- ក្នុងឆ្នាំ១៦២៣: ពួកយួនវាបានទទួលការអនុញ្ញាតិមកធ្វើជំនួញនៅព្រៃនគរ ដែលពួកវាឲ្យឈ្មោះ ថា៖ ស៊ី ហ្គន (Saigon) ។ ពួកវាបានឆ្លៀតឱកាសនូវសេចក្តីអនុញ្ញាតិនេះ ដើម្បីបញ្ជូនប្រជាជនវាជាច្រើនពាន់នាក់មករស់នៅ ។

ពួកយួនវាបានសុំសេចក្តីអនុញ្ញាតិនិងធ្វើពាណិជ្ជកម្មនៅព្រៃនគរ (Saigon) តែក្នុងរវាង៥ឆ្នាំប៉ុណ្ណោះ ។ ប៉ុន្តែក្រោយពេលនោះមកពួកយួនទាំងនោះវាមិនព្រមចាកចេញឡើយ ។

- ក្នុងឆ្នាំ១៦៤៥: ប្រទេសកម្ពុជា បានតវ៉ាសុំឲ្យប្រគល់

ព្រៃនគរមកខ្មែរវិញ ប៉ុន្តែពួកយួនវាមិនព្រមឲ្យមកវិញឡើយ។

- ក្នុងឆ្នាំ១៦៥៣: ប្រទេសកម្ពុជាបានតម្រូវសុំសិទ្ធិជាចាំបាច់ ឲ្យប្រគល់ព្រៃនគរ (Saigon) ត្រឡប់មកជាកម្មសិទ្ធរបស់ខ្មែរវិញ ព្រោះជាមាតុភូមិរបស់ខ្មែរ ។ ពួកយួនវាបានសន្យាថា និងប្រគល់ដីឲ្យមកវិញប៉ុន្តែគ្រាន់ជាការសន្យាបោកបញ្ឆោតតែប៉ុណ្ណោះ ព្រោះតាមការពិត ពួកយួនវាបាននាំគ្នា មកតាំងនៅព្រៃនគរ ចំនួនច្រើនលើសលុបសុទ្ធសឹងជាជនជាតិយួនទាំងអស់ ។ ចាប់តាំងពីការសម្រេចផលនេះមក ពួកយួនវាបានបន្តធ្វើការនទ្រានរាតត្បាត ពង្រីកទឹកដីយកមកធ្វើជាអាណានិគម និងបញ្ចូលជាឧបសម្ព័ន្ធរបស់វាជានិច្ច ។

កាលបរិច្ឆេតខាងលើនេះ ចង្អុលបង្ហាញនូវកំណត់សំគាល់នៃការជ្រៀតចូល របស់ពួកយួនមកក្នុងបូរណភាពទឹកដីរបស់កម្ពុជា ។ ប៉ុន្តែកាលបរិច្ឆេតទាំងនោះ ពុំមានន័យថា

ពួកយួនវាដណ្តើមយកទឹកដីក្នុងពេលនោះទេ ពីព្រោះជាតិខ្មែរទូទាំងប្រទេស បានតស៊ូប្រឆាំងតទល់និងការទន្ទ្រានរាតត្បាតព្រមទាំងមិនឲ្យបញ្ចូលជាឧបសម្ព័ន្ធ របស់យួនជានិច្ច ។

- ក្នុងឆ្នាំ១៦៩៩: ពួកយួនវាបានកាន់កាប់ខេត្ត បារៀ , ខេត្ត កំពប់ស្រេកាត្រី និង ព្រៃនគរ ។

- ក្នុងឆ្នាំ១៧១៥: ពួកយួនវាបានធ្វើដោយលួចលាក់កុំឲ្យរដ្ឋាភិបាលកម្ពុជាដឹង និងតាមរយៈពួកយួនដើរផ្សងព្រេងវាដើម្បីត្រួតត្រាខេត្ត ពាមបន្ទាយមាស និងខេត្ត ក្រមួនសរ ។

- នៅឆ្នាំ១៧៣២: ពួកយួនវាបានដណ្តើមការកាន់កាប់ស្រុកពាមមេសរ និង ឡុង ហោ ។

- នៅឆ្នាំ១៧៥៧: ពួកយួនវាបានសាកល្បងបោះបង្គោល នៅខេត្ត មាត់ ជ្រូក តើខ្មែរហ៊ានតវ៉ាឬទេ ? ។

- នៅឆ្នាំ១៧៥៨: ពួកយួនវាបានយកខេត្ត ព្រះត្រពាំង និងខេត្តបាសាក់ ដែលយួនវាយកស្រុក ទ្រាំង ជាទីប្រជុំស្រុក

ជាទីតាំងរបស់វា ។

ប្រជាជនខ្មែរកម្ពុជាក្រោម បានធ្វើការតស៊ូឥតឈប់ឈរ តទល់និងពួកយួនឈ្លានពាន ដើម្បីការពារទឹកដីកំណើតរបស់ខ្លួនៗ យើងគួររំលឹកអំពីព្រឹត្តិការណ៍សំខាន់ៗខ្លះដូចជា ៖

- នៅឆ្នាំ១៧៣១: ប្រជាជនខ្មែរនៅបាភ្នំនៅទិសខាងកើតនៃប្រទេសកម្ពុជា បានងើបបះបោរឡើងដេញយួនឲ្យចេញពីទឹកដីខ្មែរ ។

- នៅឆ្នាំ១៧៣៨: កងទ័ពខ្មែរ បានទៅបណ្តេញយួនចេញពីខេត្ត ពាមបន្ទាយមាស ។

- នៅឆ្នាំ១៧៤៣: ប្រជាជនខ្មែរនៅខេត្ត បាសាក់បានងើបឡើងបះបោរដេញកាប់យួន ចេញពីខេត្តទាំងអស់ ។

- នៅឆ្នាំ១៧៤៨: ប្រជាជនខ្មែរ បានបង្ក្រាំងយួន មិនឲ្យវាត្រឡប់មកវិញ ។ ហើយកងទ័ពខ្មែរបានកំទេចយួន នៅតំបន់សាបអង្គាម ក្នុងខេត្តពោធិសាត់ទៀត ។

- នៅឆ្នាំ១៧៧៦: ខ្មែរកម្ពុជាក្រោម នៅខេត្តពាម

មេសរ និងខេត្ត ឡុង ហោ បានងើបឡើងបះបោរ ជាមួយកង ទ័ពខ្មែរ បានរំដោះខេត្តទាំងពីរយកមកកាន់កាប់វិញ ។

- នៅឆ្នាំ១៨៣៥-១៨៤៧ ប្រជាជនកម្ពុជាក្រោមនៅខេត្ត ព្រះត្រពាំង បានងើបឡើងបះបោរប្រឆាំងតទល់និងយួនឈ្នានពានយ៉ាងខ្លាំងក្លា ហើយនៅឆ្នាំ១៨៤៥ ខ្មែរកម្ពុជាក្រោម បានរួមគ្នាយ៉ាងធំ តស៊ូប្រឆាំងកំទេចយួនបែកខ្ញែកអស់ ។

- នៅឆ្នាំ១៨៥៨ ប្រជាជននៅខេត្ត មាត់ ជ្រូក បានរំដោះ ហើយភ្ជាប់ទឹកដីទៅកម្ពុជាវិញ ។ ហើយកងទ័ពកម្ពុជាបានបន្ត ការដេញយួន ឲ្យចេញពីខេត្ត បាសាក់, ព្រះត្រពាំងនិងក្រមួនសរ បន្តទៅទៀត ។ ខ្មែរនៅគ្រួតត្រាខេត្តនេះរហូតដល់សម័យ អាណានិគមនិយមបារាំងសែស (ក្នុងឆ្នាំ១៨៥៣-១៩៥៤) ពួកយួនវាបានដណ្ដើមយកទឹកដី ឯទៀតៗរបស់កម្ពុជា ។ ដោយពួកយួនវាបានសមគំនិត ជាមួយអាណានិគមនិយម

បារាំងសែស ដើម្បីជួយប្ញូនយកទឹកដីនៅតំបន់ព្រៃនគរ ក្នុងឆ្នាំ ១៨៥៩ ។ ក្នុងរយៈពេលអាណានិគមនិយមបារាំងសែសនេះ កម្ពុជាបានបាត់បង់ទឹកដីដូចតទៅ ៖

- នៅឆ្នាំ១៨៧០-១៨៧៣ នៅខេត្តរោងដំរី ជាតំបន់ដែលស្ថិតនៅលើច្នេរស្ទឹង វ៉ៃកូ, នៅពាមបន្ទាយមាស នៅមាត់ជ្រូក និងនៅប្រាសាទដប់ ។

- នៅឆ្នាំ១៨៩០-១៩១៤ នៅខេត្តជើងព្រះ

- នៅឆ្នាំ១៩២៩ ពួកអាណានិគមនិយមបារាំងសែស វាបានបញ្ចូល ខេត្ត ដា ឡាក់ (Dalac) ធ្វើជាឧបសម្ព័ន្ធ ហើយប្រគល់ឲ្យទៅយួន ។

- នៅឆ្នាំ១៩៣៥ ពួកអាណានិគមនិយមបារាំងសែស វាបានភ្ជាប់កោះ ត្រាល់, កោះឬស្សី និងកោះមួយចំនួនទៀត នៅកម្ពុជាក្រោម (កូសាំងស៊ីន) ឲ្យទៅយួនថែមទៀត ។

លុះដល់សង្គ្រាមលោកលើកទី២ ពួកយួនវាបានបញ្ចូល

ទឹកដីរបស់កម្ពុជា ចំនួន ៦៧,៥០០ គីឡូម៉ែត្រការ៉េ យកទៅធ្វើជាឧបសម្ព័ន្ធ ព្រមទាំងយកប្រជាជនខ្មែរចំនួន១លាន៨សែននាក់ ទៅជាមួយផង ។

សព្វថ្ងៃនេះមានខ្មែរក្រោមចំនួនជាង ១២លាន នាក់ហើយ ។

នេះគឺជាអំពើឈ្លានពាន និងការបញ្ចូលជាឧបសម្ព័ន្ធ ដែលបានប្រព្រឹត្តរួចមកហើយ កាលពីអតីតកាល ។

បច្ចុប្បន្ននេះពួកយួនវាកំពុងបន្ត និងប្រព្រឹត្តដូចពីអតីតកាលតទៅទៀត ។ ពួកយួនវាមានលក្ខណៈដូចជា ពស់ថ្លាន់ ដែលវាកំពុងតែលេបប្រទេសដ៏ទទៀតយ៉ាងសន្សឹមៗ ទាំងទឹកដី និងទាំងប្រជាជនដោយមិនដឹងខ្លួន! ។

ប៉ុន្តែក្នុងពេលជាមួយគ្នានេះ វាបង្កចម្បាំងឈ្លានពាន ដោយអំណាចទ័ព និងប្រាជ្ញាទៅលើខ្មែរ ដើម្បីលេបយកទឹកដីនិងប្រជាពស្ត្រខ្មែរនៅកម្ពុជាថែមទៀត ។

ដូច្នេះ ទោះបីជានៅសម័យយួនសក្តិភូមិក្តី, សម័យអាណានិគមនិយមក្តី, សម័យយួនងោ ឌិញ-យីម ក្តី, សម័យយួន

ង្វៀន វ៉ាន់ ធីវ, ង្វៀន កៅ គី, ខ្មោចយួនហូ ជី មិញ និងយួនក្នុងបច្ចុប្បន្ននេះក៏ដោយ ដែលពួកយួនទាំងអស់នេះវាពុំបានផ្លាស់ប្តូរនយោបាយនិងចារិករបស់ពួកវាឡើយ គឺៈ

“លក្ខណៈឈ្លានពាន លក្ខណៈបញ្ចូលទឹកដី ប្រទេសឯទៀតៗ ជាឧបសម្ព័ន្ធសិន ហើយវានិងត្របាក់លេបទឹកដីប្រទេសទាំងនោះបន្តិចម្តងៗ ដោយរំលាយពូជសាសន៍ អារ្យធម៌ វប្បធម៌ សាសនា និងអក្សរសាស្ត្រ ដូចសម័យចម្ប៉ាទៀត ។ ”

# ២

# អំពីកម្ពុជាក្រោម

## I. តើកម្ពុជាក្រោមជាអ្វី ?

ឈ្មោះនេះជាការបកស្រាយយ៉ាងពិតប្រាកដ នៃពាក្យ " ចិនឡាទឹក " នៅដើមសតវត្សទី៨ ហើយបានរក្សាទុករហូតមកដល់សព្វថ្ងៃនេះ ដែលយើងហៅថា៖ កម្ពុជាទឹកលិច ។

កម្ពុជាក្រោម ជាផ្នែកទាំងមូលនៃជ្រោយឥណ្ឌូចិន ដែលមានឈ្មោះថា " **នគរភ្នំ, នគរគោគធ្លក** " ដែលបានហៅក្នុងរវាងសតវត្សទី១ នៃយុគ្គសម័យគ្រឹស្ត ។

ក្រៅពីកម្ពុជាបច្ចុប្បន្ននេះ អាណាចក្រនគរភ្នំ បានរួមបញ្ចូលទាំងផ្នែកខាងត្បូង និង ផ្នែកកណ្តាលនៃប្រទេសយួនទៀត គឺ:

(យួនខាងត្បូងទាំងមូល) រួមទាំងទន្លេមេគង្គកណ្ដាល នៃ (ប្រទេសលាវ) ព្រមទាំងផ្នែកទំនាប ខាងក្រោមនៃទន្លេ មេណាម (Menam)... ទាំងមូលទៀត ។

កម្ពុជាក្រោមមានទំហំ ៦៧,៥០០ គីឡូម៉ែត្រក្រឡាជាផ្នែកមួយ នៃប្រទេសកម្ពុជា បែកខាងត្បូង ហើយនៅជារបស់ខ្មែររហូត លុះរហូតដល់សម័យអណានិគមបារាំងសែស ដែលកាន់ក្ដាប់ ឥណ្ឌូចិនទាំងមូល ។

កម្ពុជាក្រោមគឺៈ ជា កូសាំងស៊ីន ដែលសព្វថ្ងៃហៅថា៖ ប្រទេសយួនខាងត្បូងឯង ។

## ១- កម្ពុជាក្រោមជាទឹកដីរបស់ខ្មែរ

អត្ថបទបុរាណជាច្រើន បានបញ្ជាក់ច្បាស់លាស់ ណាស់ក្នុងរឿងនេះ ហើយជាពិសេសអ្នកកំណត់ហេតុ ដ៏ល្បីល្បាញនៃអ្នកធ្វើដំណើរ ចិនម្នាក់ឈ្មោះ ជូ-តាក្វាន់ ( Tcheou Ta Kwan) បានកត់សំគាល់ថា៖ នៅសតវត្ស ទី១៣ ប្រទេសកម្ពុជា បានលាតសន្ធឹង ពីមាត់ទន្លេមេគង្គ រហូតដល់

ព្រំប្រទល់ខាងជើង និង ខាងកើត ។

★ *ផែនទីឥណ្ឌូចិន ក្នុងឆ្នាំ១៥៩៣* ដកស្រង់ចេញពីសៀវភៅ ផែនទីធំឈ្មោះ អ៊ួតឺលីយុស (URTELIUS) ។

ដោយយោលទៅតាមផែនទីនេះ ដីទំនាបរបស់កូសាំងស៊ីន (កម្ពុជាក្រោម) ដែលមានការបង្ហូរបញ្ចូលនូវដីល្បប់ បាន បង្កើតជា រាជាណាចក្រកម្ពុជា ហើយដីល្បប់នោះឋិតនៅបន្តរ ជាភូមិសាស្រ្តធម្មជាតិ នៃទឹកដីក្នុងសម័យគោកធ្លកពីដើម (សៀវភៅប្រវត្តិសាស្រ្ត ស្តីអំពីអាណានិគមបារាំងសែស ក្បាលទី៥ទំព័រ ៣៣៥) ។

★ *ផែនទីឥណ្ឌូចិន ធ្វើនៅឆ្នាំ១៦៣៨* (ឥណ្ឌាខាងប៉ូពាទិស ដកស្រង់ចេញពីសៀវភៅ ផែនទីធំឈ្មោះ ម៉ូរទ់តូ (Morento) ឆ្នាំ១៦២៨ ) ។

យោងតាមផែនទីនេះ កូសាំងស៊ីន (កម្ពុជាក្រោម) បច្ចុប្បន្ន ទឹកដីភាគសមុទ្រ នៃកម្ពុជាក្រោម ឋិតនៅក្នុងកម្ពុជាទាំងមូល។

កូសាំងស៊ីន (កម្ពុជាក្រោម) នេះលាតសន្ធឹង ស្ទើរហូតដល់សមុទ្រ ហើយមានព្រំប្រទល់ ដល់ផ្នែកខាងត្បូង និងទិសអគ្នេយ៍ (សៀវភៅប្រវត្តិសាស្រ្ត ស្តីអំពីអាណានិគមបារាំង ក្បាលទី៥ ទំព័រ ៣៣៥) ។

★ *ផែនទីរបស់លោក ពែរ រ៉ូត (Père Rhodes) ក្នុងឆ្នាំ ១៦៥០* កំណត់ច្បាស់លាស់ កូសាំងស៊ីនគឺអាណ្ណាម សព្វថ្ងៃដែលទំនាក់ទំនង រវាងរាជាណាច្រកចម្ប៉ា និងកម្ពុជា (ប្រវត្តិសាស្រ្តស្តីអំពី អាណានិគមបារាំង ក្បាលទី៥ ទំព័រ ៣៣១) ។

★ *ផែនទីអាស៊ីផ្នែកប៉ូពាទិស* (ភូមិភាគសមុទ្រខាងត្បូង) តាមផែនទីនេះ រាជាណាចក្រកម្ពុជា លាតសន្ធឹងពីកន្ទែងចុងសង្កាត់មាត់ញូគ នៃប្រទេសលាវ រហូតដល់សមុទ្រ (តាមឆ្នេរនៃទន្លេមេគង្គ) រួមបញ្ចូលទាំងកូសាំងស៊ីន ( កម្ពុជាក្រោម ) នៅជំនាន់អនានិគមបារាំងសែស ដែលជាផ្នែកពិតប្រាកដ នៃរាជាណាចក្រកម្ពុជា ។

★ *ផែនទីឥណ្ឌូចិនរបស់លោក រ៉ូ បែរ (Robert)* ធ្វើនៅឆ្នាំ

១៧១៧ ផែនទីនេះផ្តល់នូវភស្តុតាង ផ្សេងទៀតអំពីបូរាណភាពទឹកដីនៃកម្ពុជា (ទស្សនាវដ្តី ឥណ្ឌូចិនក្បាលទី១ ទំព័រ ១១៧) ។

★ ផែនទីឥណ្ឌូចិនផ្សាយដោយ ឌូវិល (Durville) ក្នុងឆ្នាំ ១៧៥៥ ផែនទីនេះបង្ហាញប្រាកដប្រជា នូវឯកភាពនៃទឹកដីអាណាចក្រកម្ពុជា (ទស្សនាវដ្តី ឥណ្ឌូចិនក្បាលទី១ ទំព័រ ១៣៥) ។

## ២- ប្រជាជននៅកម្ពុជាក្រោម

ដោយសំអាងទៅលើ លក្ខខណ្ឌធម្មជាតិ ដីល្អប្រសើរ ( ដីល្បប់មានជីវជាតិ ភាពងាយស្រួលក្នុងការងារកសិកម្មនិងភាពសម្បូណ៌ដោយទឹក ) ។ ប្រជាភិវឌ្ឍន៍នៅកម្ពុជាក្រោមចំរើនរហ័ស ហើយក៏បន្តរីកដុះដាល រហូតដល់សតវត្សទី១៧ ដែលជាការពិត មានប្រជាជនតែមួយគត់គឺ “ ខ្មែរ ” ។

វាមិនសមហេតុផលសោះ ដោយខ្លះបានអះអាងថា ទេសភូមិទាំងនោះ គ្មានដាំដំណាំកើត ហើយគ្មានមនុស្សរស់នៅ ម្យ៉ាងទៀតតាមការសង្កេត តាមផ្លូវអាកាស បង្ហាញថាប្រជាជនដើមក្នុងតំបន់ហ្វូណាន ដែលមានកម្ពុជាក្រោម បានធ្វើផលលិទ្ធកម្ម លើទឹកដោយការឆ្លាស់វៃ ដូចជាការបញ្ចូលទឹកឬបញ្ចេញទឹក ហើយនិងការជីកព្រែក ប្រឡាយដែលគេឃើញស្នាមដល់វាល ដែលដុះដើមដីកក់ជុំជិត ។

ដូច្នេះកាលពីជំនាន់មុន ប្រជាពលរដ្ឋជាច្រើន បានរស់នៅក្នុងដែនដីនេះ ដែលមនុស្សកកាយដី ដើម្បីដាំដំណាំចិញ្ចឹមជីវិត ។ ចាប់តាំងពីសតវត្សទី១៧មក ពួកយួន (អាណ្ណាម) ដែលមកដល់ទីនេះ ត្រូវប្រើការរឹបជាន់យ៉ាងព្រៃផ្សៃ ដើម្បីមករស់នៅជំនួសប្រជាជន ខ្មែរដើម “ខម” ទៅវិញ ។

ភស្តុតាងដែលប្រជាជន រស់នៅបន្តក្នុងដែនដីកូសាំងស៊ីន (កម្ពុជាក្រោម) មានចំនួនច្រើនហើយប្លែកៗ ពួកទេសចរដែលធ្វើដំណើរចុះឡើង ពេញកម្ពុជាក្រោមក៏ពុំភ្លេចនឹងពិនិត្យ

អំពីវត្តមាននៃប្រាង្គប្រាសាទ នឹងវិហារពីសម័យបុរាណ រូបបដិមាករ នៃព្រះអទិទេព ព្រមទាំងវត្តអារាមរាប់រយដែលមានរចនាបុថខ្មែរសុទ្ធសាធ ថែមទាំងដោយភិក្ខុសង្ឃខ្មែរព្រះសង្ឃធ្វើកិច្ច ប្រតិបត្តិសាសនាហិនយាន្ត"ឬយានជំនិះតូច" ដូចអ្នកសាសនិក ដែលប្រៀនប្រដៅធម៌ នៅកម្ពុជាដែរ ។ ពួកទេសចរទាំងនោះ ក៏ឃើញខ្មែរនៅតែ រក្សាទំនៀមទម្លាប់ នឹងប្រពៃណីយ៍ដដែល ហើយប្រតិបត្តិតាម សាសនាដូចជាបងប្អូនរួមឈាម នៅកម្ពុជាផងដែរ ។

ប្រជាជនខ្មែរមានចំនួនប្រមាណ ១៥១.០០០ ក្នុងឆ្នាំ ១៨៨៨ មានកំរើតមកដល់ឆ្នាំ១៩៥៤ ជាង២.៦ លាននាក់ ដែលគេចាត់ទុក ជាជនជាតិភាគតិច យ៉ាងសំខាន់ក្នុងស្រុក ។

## II. ចូលមកដល់រឿងយួន (អាណ្ណាម)

គឺចាប់តាំងពីសតវត្សរ៍ទី១៧មក ដែលយួនជាវិប្រជា (Feuflade) (ពួងចិន) មានដើមកំណើតនៅប្រទេសចិនខាងត្បូងដើម្បីមករស់នៅដោយសារ ប្រជាជនកម្ពុជាក្រោមក្រោយដែលបានបំផ្លាញខ្ទេចខ្ទី និងទន្ទ្រានរាតត្បាត យ៉ាងសាហាវ ព្រៃផ្សៃ យកប្រទេសចម្ប៉ាមក ។

មុនតំបូងយួនវាមានចំនួនតិចតួចទេ វានាំគ្នាមករស់នៅតាមរយៈការអនុញ្ញាតិរបស់ព្រះមហាក្សត្រខ្មែរ ក្នុងខេត្តទាំងបីគឺ: ព្រៃនគរ, បៀន ហ្វា និង បារៀ (Saigon, Bien Hao,Baria)

បន្តិចម្តងៗ ពួកដែលគេនិរទេសនេះ ជាមនុស្សសោតអណ្តែតនិងទាហានបាក់ទ័ពពីចិន សុទ្ធសឹងតែគ្មានផ្ទះសម្បែង ប៉ុន្តែគេមានការអត់ធន់ តស៊ូក្លាហាន ហើយធ្លាប់មានការចិញ្ចឹមជិវិត ដោយត្រជាបត្រដួស បាននាំគ្នាចូលមកយ៉ាងសន្ធឹកសន្ធាប់ រស់នៅក្នុងទីរួមខេត្តយ៉ាងកុះករ ហើយវាបាន

រុញច្រានប្រជាជនខ្មែរ កាន់តែខ្លាំងឡើងៗ ទៅទិសខាងលិច ឬ (បញ្ចឹមទិស) ។

ការទន្ទ្រានរាតត្បាតនេះតំបូង វាបានធ្វើដោយសន្តិភាព ក្រោយមកបានត្រូវទំនុបបំរុង និងបំផុសគំនឹតដោយរាជបរិពារក្រុងហ្វេ ដែលអធិរាជទាំងនេះ មិនកោតញញើត និងទៅសុំជំនួយពីពួកមេចោរប្លន់ចិន ឈ្មោះ ម៉ាក់ គូ (Mac Cuu) ដើម្បីប្លន់ដណ្តើមយកខេត្ត ហាទៀង (Hatien) ។ បន្ទាប់មកទៀតពួកយួន (អាណ្ណាម) វាបានគំរាមកំហែងខ្មែរបង្ករសង្គ្រាម ហើយសង្គ្រាមទាំងនោះ បានធ្វើឲ្យយួនប្លន់យកទឹកដីខ្មែរបន្តិចម្តងៗ នៅកូសាំងស៊ីន គឺ (កម្ពុជាក្រោម) ។

ប្រវត្តិសាស្ត្រនៃកម្ពុជា ក្នុងចន្លោះឆ្នាំ១៦៥០ និង១៨៦០ គេបានកត់សំគាល់ថា មានចម្បាំងជាច្រើន ដែលខ្មែរត្រូវច្បាំងតតាំង ជាមួយពួកយួនប្លន់ទឹកដី ដើម្បីរំដោះមាតុភូមិ ដែលយួនឈ្លានពាន ដោយអយុត្តិធម៌ ។

នយោបាយពង្រីកទឹកដី និងបំណងចង់ដាក់កូសាំងស៊ីន

"កម្ពុជាក្រោម" ឲ្យនៅក្រោមអធិបតេយ្យភាពរបស់យួន ធ្វើដោយស្តេចក្រុងហ្វេ បានធ្វើឲ្យមានប្រតិកម្មយ៉ាងខ្លាំងដល់ព្រះមហាក្សត្រ និងប្រជារាស្ត្រខ្មែរ ។

ការប៉ុនប៉ងរំដោះទឹកដី បានត្រូវអនុវត្តន៍ដោយព្រះមហាក្សត្រខ្មែរ ឬប្រជាជនខ្មែរ ដើម្បីវាយដណ្តើមយកខេត្ត ដែលយួនយកដោយខុសច្បាប់ និងអយុត្តិធម៌មកវិញ ។

គេអាចរំលឹកនូវ ព្រឹត្តិការណ៍ដ៏សំខាន់ៗ ដូចតទៅនេះ ៖

១- ក្នុងឆ្នាំ ១៦៥៨ ចម្បាំងទី១នៅក្បែរបារៀ (Baria) រវាងយួននិងខ្មែរ ។

២- ក្នុងឆ្នាំ ១៧៣៩ ព្រះបាទធម្មោរាជាទី៣ ( King Thommo Reachea III ) ប្រមូលអាវុធ ដើម្បីដេញយួនឈ្លានពាន ចេញពី " ហា ទៀង " (Hatien) ដែលពួកយួនវាចូលមកនៅ ហើយការពារយ៉ាងមាំមួនជាទីបំផុត ។

៣- ក្នុងឆ្នាំ១៧៤៣ ឧកញ្ញានរិន្ទ្រ (Oknha Norintra) ចៅហ្វាយស្រុកបាសាក់ ដឹកនាំខ្មែរដើម្បីដេញ

ចោរប្អូនយួនពីតំបន់នោះ បង្ខំពួកវាឲ្យចាកចេញទៅ កោះកាហុង ពាមមេសរ (Ca-hong Peam Me sâr) - (My tho) ។

៤- ក្នុងឆ្នាំ ១៧៧៦ ព្រះបាទអង្គនន្ទ បានដណ្ដើមយកខេត្តវិញឡុង (Vinh Long) និង មីថូ (My tho) ដោយរួមជាមួយខ្មែរដែលរស់នៅ កូសាំងស៊ីន (កម្ពុជាក្រោម) ទាំងមូលនោះ ។

៥- នៅចន្លោះឆ្នាំ ១៨២២ និង ឆ្នាំ ១៨៤១ នៅខេត្តព្រះត្រពាំង (Travinh) ។

ដែលមានប្រជាជន និង ចៅហ្វាយស្រុកព្រះត្រពាំង (Preah Trapeang) ជាមេ បានបះបោរតទល់ និងពួកយួនវាដណ្ដើមទឹកដី ដែលវាបានបង្ខំខ្មែរឲ្យបោះបង់ទំនាមទម្លាប់ ប្រពៃណី សាសនា និងភាសា ។ មេទ័ពខ្មែរម្នាក់ឈ្មោះ ទេសា-សោម (Tessa Som) រួមជាមួយអនុសេនីយត្រី ឯក-ព្រុញ (Ek-Pronh) នឹង ម៉ឺន-សោម ដឹកនាំចលនាតស៊ូខ្មែរ តទល់និងយួនឈ្លានពាន ដើម្បីដណ្ដើមយកដីរបស់បុព្វបុរសមកវិញ ។

៦- ក្នុងឆ្នាំ ១៨៥៨: ព្រះបាទ "អង្គ ឌួង" បាន រៀបចំបេសកកម្មមួយ ដើម្បីទៅជួយខ្មែរ នៅមាត់ជ្រូក (Chau Doc) ដែល ត្រូវយួនជិះជាន់សង្កត់សង្កិន ។ លោកឧញ្ញាកែប (Kep) ចៅហ្វាយខេត្តទ្រាំង (Treang) មានជ័យជំនះលើ ពួកយួន នៅខេត្តមាត់ជ្រូក (Chau Doc) ហើយរៀបចំកងទ័ព ប្រដាប់អាវុធនៅផ្ទៃក្នុង នៃកូសាំងស៊ីន ស្រាប់តែព្រះបាទ អង្គ ឌួង ទ្រង់ចូលទីវង្គត់ ដែលធ្វើឲ្យមេទ័ពទាំងនោះពុំមាន លទ្ធភាពបន្តបេសកកម្មតទៅទៀត ។

៧- ក្នុងឆ្នាំ១៨៦១: មេបញ្ជាការខ្មែរឈ្មោះ លី-រ័ត្ន (Li Roth) បានយកជ័យជំនះ លើតំបន់ឆ្នេរសមុទ្រ រហូត ដល់ ព្រែកឫស្សី (Cantho) ។ ប៉ុន្តែមានគ្នាគាត់ម្នាក់ ក្បត់ជាតិ ចូលដៃយួន គាត់ត្រូវបញ្ឈប់ការបះបោរនោះភ្លាម ។

ដូចយើងបានឃើញមកហើយ គ្មានអ្វីជាសំនួរចោទទេ ហើយគ្មានឱកាសណាមួយ នៅក្នុងប្រវត្តិសាស្ត្រយើង ដែល មហាក្សត្រខ្មែរ និងប្រជារាស្ត្រយើង ត្រូវលះបង់នូវសិទ្ធិកាន់

កាប់ទឹកដីកូសាំងស៊ីនរបស់យើង ដោយពេញច្បាប់នោះទេ ។ ការប៉ុនប៉ង នឹងយកទឹកដីមកវិញ ដោយកម្លាំងអាវុធ បានត្រូវ ចាត់ចែងដោយ មហាក្សត្របន្តបន្ទាប់ និងដោយប្រជារាស្ត្រ ខ្មែរ រហូតដល់អន្តរាគមន៍បារាំង នៅឥណ្ឌូចិនដែលបានបញ្ចប់ មួយរយៈ នូវការតស៊ូប្រឆាំង ក្នុងការទាមទារទឹកដី របស់ដូន តាយើងមកវិញ ។

## III. អន្តរាគមន៍បារាំងសែសនៅឥណ្ឌូចិន

បារាំងបានមកដល់ព្រៃនគរ និងក្នុងភូមិភាគជិតខាង នេះរវាងឆ្នាំ ១៨៥៩ ។ ក្រោយសម័យសន្តិភាព ពួកបារាំងបាន ដាក់តុងកឹង (Tonkin) អាណ្ណាម, កម្ពុជានិងលាវ ក្រោមអាណា និគមនិយមបារាំង ហើយយកកូសាំងស៊ីន (កម្ពុជាក្រោម) ទឹកដីរបស់ខ្មែរធ្វើជាអាណានិគម ដែលប្រជាជនខ្មែររស់នៅ ទុកដូចជារបស់ពួកបារាំងសែស ។

ភាពខុសគ្នាក្នុងរបប អាណាព្យាបាលបារាំង និង អាណានិគម

និយម នាំឲ្យបារាំងអនុវត្តន៍ ការគ្រប់គ្រងផ្សេងៗគ្នា ចំពោះប្រទេសទាំងនោះ ។

ដូច្នេះហើយបានជាសកម្មភាពរបស់បារាំង ក្នុងវិស័យសេដ្ឋកិច្ច និងសង្គមកិច្ច ធ្វើឲ្យឃើញយ៉ាងច្បាស់ នៅប្រទេសដែលរស់នៅក្រោមអាណានិគមនិយម ជាងនៅក្នុងប្រទេសដែលបារាំងបានធ្វើជាអាណាព្យាបាល ។

ចំនួនប្រជាជនបារាំង ដែលមកតាំងទីលំនៅ នៅកូសាំងស៊ីន (កម្ពុជាក្រោម) ពាណិជ្ជករ ឬប្រជាជនអាណានិគម មានចំនួនច្រើនលើសលុប ជាងប្រទេសដទៃទៀតនៅឥណ្ឌូចិន ដើម្បីឲ្យមានផលប្រយោជន៍ ដល់ជនជាតិរបស់គេ ដូច្នេះហើយបានជាបារាំង មានលទ្ធភាពនិងច្រើមធំពាសមេឃ ហ៊ានបញ្ចូលទឹកដីកម្ពុជាក្រោម ឲ្យទៅជាស្រុកអាណានិគមរបស់គេ ។

ហេតុដូច្នេះហើយ បានជាទឹកដីទាំងមូលនៅកម្ពុជាក្រោម ដែលនៅក្រោមអំណាចផ្ទាល់ របស់ព្រះមហាក្សត្រខ្មែរ ដូចជាស្រុក ស្វាយ-ទង (Trilon) ខេត្ត តាយ-និញ

(Tay Ninh) ដែលមានប្រជាជនខ្មែររស់នៅ បានត្រូវភ្ជាប់ទៅនិងដែនដីកូសាំងស៊ីន (កម្ពុជាក្រោម) ដោយសារបារាំងជាអ្នកសម្រេច កាលណោះបារាំងបានប្រើ អំណាច និងសទ្ធិសេរីភាពទាំងមូល ក្នុងការកំរឹតព្រំដែន របស់កម្ពុជានិងកម្ពុជាក្រោម ។

ប៉ុន្តែក្រោមការអភិបាលរបស់បារាំង (ក្នុងឆ្នាំ ១៨៦២-១៩៤៥) ខ្មែរនៅកម្ពុជាក្រោម សប្បាយរីករាយនិងច្បាប់ ទូលំទូលាយរបស់បារាំង បន្តិចបន្តួចដែរ ហើយគេទុកប្រជាជនខ្មែរដើម ១ម ដែលនៅទីនោះឲ្យមានភាពស្មើៗគ្នា ជាពិសេសប្រជាជនខ្មែរ មានសទ្ធិដូចតទៅនេះ ៖

- ★ ច្បាប់ (សិទ្ធិ) អាចទៅមន្ទីរពេទ្យសាធារណៈដោយមិនចាំបាច់បង់លុយ ។
- ★ មានសិទ្ធិអាចទទួលកម្មសិទ្ធដីធ្លីនិងផ្ទះសម្បែង ។
- ★ លទ្ធកម្ម ( អាចមានសទ្ធិទិញ-ដូរ ) ។
- ★ ការផ្គត់ផ្គង់ប្រាក់កាស់ដោយអាជ្ញាធរសាធារណៈ

ក្នុងស្ថាប័នសិក្សាធិការខ្មែរ ។

★ សិទ្ធិទទួលអាហាររូបករណ៍សំរាប់ការសិក្សាដើម្បី អនុគ្រោះដល់និសិត្សខ្មែរ សេរីភាព សមាគម ។

★ សេរីភាពក្នុងការប្រើប្រាស់ភាសារកំណើត ។

★ សេរីភាពនៃចរាចរនិងគមនាគមន៍រវាងកម្ពុជា និងកូសាំងស៊ីន (កម្ពុជាក្រោម) ។

★ សេរីភាពនៃពាណិជ្ជកម្មនិងសហគ្រាស ។

★ សេរីភាពនៃមនសិការ-គោរពបូជានូវពិធីបុណ្យ និងសាសនា ។

ក្នុងសម័យត្រួតត្រា នៃអាណានិគមបារាំងសែស ខ្មែរនៅកម្ពុជាក្រោម ពុំដែលបានតវ៉ាអ្វីទេ ព្រោះយើងពុំអាចធ្វើទៅបាន ពិតមែនហើយ ចំពោះប្រជាជនខ្មែរ នៅកូសាំងស៊ីន (កម្ពុជាក្រោម) បារាំងបានអនុវត្តន៍ នយោបាយបញ្ចូលទឹកដីជ្រួលហួសហេតុ ក៏ប៉ុន្តែច្បាប់និងសេរីភាព នៅតែមានជាមូលដ្ឋានជានិច្ច រវាងជនជាតិភាគតិចខុសៗគ្នា ដែលរស់នៅ

កម្ពុជាក្រោម ឬហៅថា យួនខាងត្បូងសព្វថ្ងៃនេះ ។

នេះមិនមែនជាគម្រោងនយោបាយ ដែលរដ្ឋអំណាចបន្តបន្ទាប់នៅយួនខាងត្បូង តាំងពីការទាមទារឯករាជ្យពីបារាំងសែស ក្នុងឆ្នាំ១៩៤៥ នោះទេ ជាពិសេសគឺចាប់តាំងពីឆ្នាំ១៩៤៨ មក ដែលនយោបាយ ប្រល័យពូជសាសន៍ ក៏រឹតខ្លស់របស់យួន បានអនុវត្តន៍ដោយមនសិការ ហើយដោយព្រៀងទុកជាមុន ចំពោះ ខ្មែរនៅកម្ពុជាក្រោមទាំងមូល ។

## IV. អន្តរាគមន៍និងគម្រោងដើម្បីអន្តរាគ្រោះដល់កម្ពុជាក្រោម

អន្តរាគមន៍បារាំង នៅឥណ្ឌូចិនបានបំបាត់ សង្គ្រាមឥតឈប់ឈរ រវាងខ្មែរនិងយួនអាណ្ណាមនៅឥណ្ឌូចិន ហើយអន្តរាគមន៍នេះ បានប្រែក្លាយទៅជាអាណានិគមបារាំង។

ក្នុងឆ្នាំ ១៦៤៥: ព្រះបាទស្រីធម្មរាជារាមាធិបតី (Çri Thommreachea Reama Thippadei) បានធ្វើការទាមទារទឹកដីដល់អធិរាជអាណ្ណាម ហើយព្រះបាទ “អង្គឌួង” ក៏បាន

ទាមទារឡើងវិញ ក្នុងឆ្នាំ ១៨៥៧ ដែរ ។

ព្រះបាទអង្គឌួង បានសុំអន្តរាគមន៍ ពីអធិរាជបារាំង ដើម្បីយកខេត្តរបស់ខ្មែរ នៅកូសាំងស៊ីន (កម្ពុជាក្រោម) មកវិញ នៅក្នុងឆ្នាំ ១៨៥៧ ។

ព្រះបាទសម្ដេចនរោត្តម ក្នុងឱកាសព្រះរាជដំណើរទៅកាន់ព្រៃនគរក្នុងឆ្នាំ១៨៦៤ (មួយឆ្នាំក្រោយចុះហត្ថលេខាអំពីសន្ធិសញ្ញា អាណាព្យាបាលរបស់បារាំង នៅកម្ពុជា) បានធ្វើអន្តរាគមន៍ ដើម្បីទាមទារយកខេត្តខ្មែរ នៅកូសាំងស៊ីន (កម្ពុជាក្រោម) ជាម្ចាស់ទឹកដីមកវិញ ។

ក្រោមការកាន់កាប់ របស់រដ្ឋអំណាចជប៉ុន ព្រះមហាក្សត្រនរោត្តមសីហនុ បានធ្វើគម្រោង យ៉ាងជាក់លាក់អំពីច្បាប់ឃួនចូលមកនៅកូសាំងស៊ីន (កម្ពុជាក្រោម) គោលបំណងរបស់ព្រះអង្គគឺ៖ ចង់ធ្វើឲ្យបានសម្រេចជាឯកភាព ដោយបញ្ចូលទឹកដីនៅកម្ពុជាក្រោម មកជាទឹកដីខ្មែរវិញ ។

នៅពេលដែលប្រទេសបារាំង យល់ព្រមសេចក្ដីស្នើរសុំរបស់

ស្តេចយួន ប៉ៅដាយ (Bao Dai) អំពីឯកភាពនៃប្រទេស៣ ដែលហៅថា ប្រទេសគី (Ky) មាន៖ (តុងកឹង, អាណ្ណាម និង កូសាំងស៊ីន ឬ(កម្ពុជាក្រោម) ព្រះបាទសម្តេចនរោត្តមសីហនុ ឧបយុវរាជវរ័ន្ទ បានផ្ញើចុតម៉ាយមួយ នៅថ្ងៃ ទី២០ ខែមករា ឆ្នាំ ១៩៤៨ ដើម្បីសុំឲ្យអគ្គស្នងការជាន់ខ្ពស់បារាំង នៅឥណ្ឌូចិន ដឹងឮអំពីកិច្ចចរចារ ដែលបារាំងបានសន្យានិងធ្វើជាមួយប្រទេសយួន ។

ប៉ុន្តែផ្ទុយទៅវិញ វាបានរំលងនិងការទាមទាររបស់ខ្មែរ បារាំងបានចុះហត្ថលេខា ជាមួយស្តេច "ប៉ៅដាយ" (Bao Dai) អំពីកិច្ចព្រមព្រាងនៅឆ្នេរសមុទ្រដាឡុង(Bay d'Long) ក្នុងឆ្នាំ ១៩៤៨ ដោយទទួលស្គាល់គោលការណ៍ ឯកភាពនៃប្រទេស ៣ (Ky) (តុងកឹង, អាណាម និងកូសាំងស៊ីន ឬ កម្ពុជាក្រោម)។

ព្រះបាទសម្តេចនរោត្តមសីហនុ ឧបយុវរាជវរ័ន្ទ បាន តវ៉ាប្រឆាំងនិងកិច្ចព្រមព្រាងនេះ ដោយទ្រង់បានផ្ញើចុតម៉ាយ មួយទៀត នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៤៨ ហើយទ្រង់ក៏

បានបញ្ជូនគណៈប្រតិភូមួយ នៅឆ្នាំ១៩៤៩ ដើម្បីធ្វើការតាមដានអំពីការបរបារ របស់សភាតំណាងរាស្ត្រ ស្តីអំពីច្បាប់ទាក់ទង និងការកែប្រែលក្ខន្តិកៈ នៃទឹកដីកូសាំងស៊ីន ឬកម្ពុជាក្រោម ហើយដើម្បីរៀបចំយ៉ាងជាក់លាក់ ពីការតវ៉ាប្រឆាំង និង ការបញ្ចូលទឹកដីខ្មែរ កូសាំងស៊ីន ឬ កម្ពុជាក្រោមប្រគល់ឲ្យទៅប្រទេសយួនដោយខុសច្បាប់ ។

នៅពេលបញ្ចប់ កិច្ចសន្ធិសញ្ញាបារាំង-ខ្មែរ នាថ្ងៃទី៨ ខែវិច្ឆកា ឆ្នាំ១៩៤៩ ព្រះបាទសម្តេចនរោតម្តសីហនុ ឧបយុវរាជវរ័ន្ទ បានប្រកាសជាឧឡាឫកថា៖

“សន្ធិសញ្ញានេះទុកជាមោឃៈ” ក្នុងនាមជាប្រជាជនខ្មែរ ដែលត្រូវបោះបង់ សិទ្ធសញ្ញា និងផលប្រយោជន៍របស់ខ្លួននៅកូសាំងស៊ីន ឬ កម្ពុជាក្រោម ។

ឯកឧត្តម សឺន-សាន (Son San) ក្នុងឱកាសសម័យប្រជុំគណៈរដ្ឋមន្ត្រី ជាន់ខ្ពស់បារាំងនាថ្ងៃ ទី២៩ ដល់ថ្ងៃទី៣០ វិច្ឆិកាឆ្នាំ១៩៥១ បានសើរើរំលឹកឡើងនូវ អន្តរាគមន៍

ធ្វើដោយព្រះបាទសម្ដេចនរោត្តមសីហនុ ក្នុងរឿងទឹកដីកូសាំងស៊ីន ឬ កម្ពុជាក្រោមនេះ ។

នៅសន្និសិទ្ធក្រុង ហ្សឺណែវ (Genève) ក្នុងឆ្នាំ១៩៥៤ ឯកឧត្ដម ទេព-ផន (Tep Phan) ប្រធាននៃគណៈប្រតិភូខ្មែរ បានសើរើឡើងវិញ នូវការព្រាងទុករបស់រាជរដ្ឋាភិបាលខ្មែរ ក្នុងសេចក្ដីប្រកាសជាផ្លូវការ ។

គណៈប្រតិភូខ្មែរ សុំឲ្យសន្និសទ្ធិ ទទួលពិនិត្យនូវប្រយោគនៃកិច្ចសំរេច ស្ដីអំពីការរួមបញ្ចូលទឹកដី កម្ពុជាក្រោមទៅឲ្យប្រទេសយួនយៀកណាមខាងត្បូង ប្រយោគនេះគ្មានជំពាក់ទាក់ទងទៅ និងការបោះបង់ចោល សិទ្ធនិងគុណប្រយោជន៍ដ៏ត្រឹមត្រូវតាមច្បាប់ ដែលប្រជាជនខ្មែរទាំងអស់ អាចប្ដឹងទាមទារ យកមកជាម្ចាស់ទឹកដីវិញ នៅឯយួនខាងត្បូងឡើយ ហើយចំពោះរឿងនេះ កម្ពុជាបានរៀបចំ យ៉ាងជាក់លាក់នូវគំរោងការណ៍ យ៉ាងឆាប់រហ័ស ជាពិសេសគឺ នូវពេលចុះហត្ថលេខា នៃសន្ធិសញ្ញា បារាំង-ខ្មែរ នាថ្ងៃទី៨ វិច្ឆិកា ឆ្នាំ

១៩៤៩ ក្នុងការទាក់ទងកម្ពុជា និងបារាំងហើយនិងនៅពេលបោះឆ្នោត អំពីច្បាប់បារាំង ដែលភ្ជាប់ទឹកដី កូសាំងស៊ីន ឬ កម្ពុជាក្រោម ទៅឲ្យប្រទេសយួន ។

ទីបំផុត ក្នុងឱកាសប្រជុំទី១២ នៅសភាទូទៅ នៃអង្គការសហប្រជាជាតិ សម្តេច ប៉ែន-នុត ប្រធាននៃគណៈប្រតិភូខ្មែរ បានចែកជូនដល់ ប្រទេសជាសមាជិកនូវ ញាណសក្ត៍ (Memmoire) មានចំណងជើងថា " កំណត់ប្រវត្តិរបស់កម្ពុជា អំពីទឹកដី នៅប្រទេសយួនខាងត្បូង " ។

## V. សេចក្តីសន្និដ្ឋាន

ដូចយើងបានឃើញមកហើយ កម្ពុជាក្រោមគឺជាផ្នែកខាងត្បូងដែលសព្វថ្ងៃគេហៅថា "យួនខាងត្បូង" ជាដីរបស់ខ្មែរយ៉ាងពិតប្រាកដ ហើយតាមទស្សនៈ ជាច្រើន ដូចជាតាម ទស្សនៈបុរាណវត្ថុវិទ្យា ទស្សនៈខាងផែនទី ទស្សនៈខាងប្រវត្តិសាស្ត្រ ទស្សនៈខាងជាតិនិពន្ធ និង ទស្សនៈខាងតុលាការ ។

កម្ពុជាក្រោមមិនមែនត្រូវវាយលុក ដោយកម្លាំងទ័ពយួនជាស្ថាពរនោះទេ មួយផ្នែកទៀតចម្បាំង មិនដែលចប់ដោយជោគជ័យជាស្ថាពរឡើយ ហើយការកាន់កាប់របស់ពួកយួន ក៏មិនដែលជាអចិន្ត្រៃយ៍ដែរ ដូច្នេះយួនវាពុំអាចមានប្រៀបទៅលើការវាយលុកបានទេ ។

ម្យ៉ាងវិញទៀត គ្មានសន្ធិសញ្ញាណាមួយ គ្មានកិច្ចព្រមព្រាងណាមួយ ដែលចុះសេចក្តីសំរេច រវាងខ្មែរនិងយួន

ស្តីអំពី ការបោះបង់ចោលទឹកដី កម្ពុជាក្រោមនោះឡើយ ។

ក្នុងឆ្នាំ ១៨៦៣ កម្ពុជាក្រោមគឺ ឋិតនៅក្រោមការកាន់កាប់គ្រប់គ្រងរបស់ ព្រះមហាក្សត្រខ្មែរនៅឡើយ ហើយក៏មិនបានអនុញ្ញាតឲ្យយួន បញ្ចប់សេចក្តីព្រមព្រាង ជាមួយបារាំងអំពីទឹកដីកម្ពុជាក្រោមដែរ ។

ផ្ទុយទៅវិញ ទោះជាខ្មែរត្រូវគេប្លន់យកទឹកដី ដោយមិនចេញស្តីក៏ដោយ អ្នកនិពន្ធបារាំងម្នាក់បានចោទសួរថា៖ “ តើខ្មែរបោះបង់ចោលនូវគំនិត ទាមទារទឹកដីយកមកវិញក្នុងពេលនេះ ឬ នៅក្នុងអនាគតដែរឬទេ? ”
គាត់បានបន្ថែមទៀតថា៖ “ តើវិន័យនៃ អាជ្ញាយុកាល[១] អាចអនុវត្តដោយរបៀបប្លន់ទឹកដី របស់អ្នកជិតខាងនោះឬ? ” ។
ប៉ុន្តែនៅក្នុងពេល ប្រកាសឯករាជ្យ ពីអាណានិគមបារាំងក្នុងឆ្នាំ១៩៤៥ ប្រទេសបារាំង បានផ្ទេរទឹកដីកម្ពុជាក្រោមព្រមទាំងប្រជារាស្ត្រ ឲ្យទៅប្រទេសយួន ដោយរំលោភនិងដោយផ្ទុយពីឆន្ទៈ របស់ប្រជាជនខ្មែរ ។ មហាសន្និបាតនៅ

ក្រុងហ្សឺណែវ (Genève) នាថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៥៤ ដែលពុះចែកប្រទេសយួន ជាពីរផ្នែក ក៏ពុំបានផ្លាស់ប្តូរអ្វីនូវស្ថានភាព កូសាំងស៊ីន ឬកម្ពុជាក្រោមពីមុនដែរ ក្នុងរាជ្យបារាំង ដែលនៅតែជា ទឹកដីរបស់ខ្មែរជាដរាប! ។

---

<u>អាជ្ញាយុកាល</u>[១] = ជាច្បាប់មួយបែបឲ្យមានលទ្ធកម្ម នូវកម្មសិទ្ធិកាន់កាប់ដីជានិច្ច បើដៃគូរម្នាងទៀតជាម្ចាស់សិទ្ធ នៅដេកស្ងៀមមិនរួបរួមគ្នា ធ្វើការប្តឹងផ្តល់ទៅតុលាការទេ ឬដោយមធ្យោបាយណាមួយ ។

# ៣

## ការប្រល័យពូជសាសន៍ អនុវត្តន៍ ដោយ រដ្ឋាភិបាលយួនវៀតណាម

ពួកយួនដែលមានតំណវង្សអំបូរ ដូចជាជនជាតិថៃដែរ បានចូលមកដោយបំពាន ដើម្បីទាក់ទងជាមួយជនជាតិខ្មែរ ដែលជាម្ចាស់ស្រុកមុនគេនៅឥណ្ឌូចិន ក្នុងពេលជាមួយជនជាតិមន នឹង ចាម ។

ពួកនេះពុំបានធ្វើតាមអំបូរខ្លួន ដែលរក្សាជាមួយគ្នាពីបុព្វបុរសទេ ផ្ទុយទៅវិញវានាំគ្នាមកច្បាំងយ៉ាងស្វិតស្វាញ ដើម្បីសម្លាប់ខ្មែរយើងឲ្យផុតពូជ និងបំផ្លាញវប្បធម៌យើងឲ្យវិនាសសាបសូន្យថែមទៀត ។

អធិរាជយួន មិញ ម៉ាង (Minh Mang) (១៨២០-១៨៤១)

បានតែងតាំងម្ចាស់ក្សត្រី អង្គមី (Ang Mey) (១៨៣៤-១៨៤១) ឲ្យសោយរាជបន្តពីព្រះបិតា ។

ក្នុងរជ្ជកាលក្សត្រី អង្គម៉ី ប្រទេសខ្មែរនឹងកម្ពុជាក្រោមឋិត នៅក្រោមអំណាចត្រួតត្រារបស់យួនអាណ្ណាម ។ ពេលនោះយួនវាបានប្រើអំណាចបំបាត់ទំនៀមទំលាប់ប្រពៃណី ភាសា និងជំនឿ ដែលជាឫសរបស់ខ្មែរទាំងអស់ ។

ដោយសំអាងទៅលើបទបញ្ជា របស់អធិរាជយួន អំណាចអធិបតេយ្យទាំងមូល ធ្លាក់មកក្នុងកណ្តាប់ដៃរបស់ឧត្តមសេនិយ៍បីនាក់ ដូចជា ទ្រឿង មិញ យ៉ាង (Truong Minh Giang) ។

មានខេត្តខ្លះត្រូវប្តូរដាក់ឈ្មោះជាយួន ដូចជា (ភ្នំពេញ ក្លាយទៅជា **ណាំ យ៉ាង**, បាភ្នំ ទៅជា **បាឡេ**, ព្រៃវែង ទៅជា **ឡូវែន**, ផ្សារដែក ទៅជា **សាដេក**, ស្រុកទ្រាំង ទៅជា **សុកចាំង** កំពង់ស្ពឺ ទៅជា **ប៊ុងប៊ី** ) ។ល។

ហើយចៅហ្វាយខេត្តខ្មែរ ត្រូវមានបេសកជនយួន(វ៉េស៊ីដង់)

ត្រួតពិនិត្យ នូវគ្រប់សកម្មភាពរាជការទាំងនោះ ។ ឥស្សរៈជនខ្មែរទាំងនោះ ត្រូវស្លៀកពាក់ខោអាវយួនហើយបួងសក់យួន។ យួនវាបានបង្ខំឲ្យខ្មែរប្រើភាសាយួនក្នុងរដ្ឋបាល ហើយសង្កត់សង្កិន ព្រះសង្ឃណាដែលគេសង្ស័យថា នៅមានចិត្តស្នេហាមាតុភូមិ។ យួនវាបានកាប់រំលំដើមឈើពិសិដ្ឋ បំផ្លាញរូបបដិមាករ ព្រះពុទ្ធនិងស្តូប ឬប្រាង្គដ៏កល់សព ។ រីឯដីធ្លីរបស់ខ្មែរត្រូវចែកចាយទៅឲ្យទាហានយួន ដែលរំលោភយក ដោយកម្លាំងទ័ព (ទាហានកសិករ) ហើយតាំងទីលំនៅ ជាគ្រួសារៗ ដើម្បីកាន់កាប់ដីជាស្ថាពរ ។

វិធានការចុងក្រោយរបស់ ទ្រឿង មិញ យ៉ាង នៅក្រោមរជ្ជកាល របស់យួន ធៀវ ទ្រី ( Thieu Tri ) រវៀងឆ្នាំ ( ១៨៤១-១៨៤៧ ) គឺការជំរឿនប្រជាជន ដាក់ក្នុងបញ្ជីរស៊ុរិយោដី នូវកម្មសិទ្ធិឯកជន បន្ទាប់មកការបំបាត់ ទំនៀមទំលាប់ប្រពៃណីនិងសាសនារបស់ខ្មែរ។ ការបះបោរនៃប្រជាជនខ្មែរបានត្រូវយួនបង្ក្រាប ដោយគ្មានអាណិតអាសូរ ។

ក្រោមរជ្ជកាលរបស់យួន ទូ ឌុក (Tu Duc) ដែលបន្ត ពីឪពុកវា ។

នយោបាយឈ្លានពានរបស់យួន បានត្រូវអនុវត្តន៍កាន់តែ សាហាវ តឹងរឹងឡើងៗ ឥតត្រាប្រណី លើសពីរជ្ជកាលមុនៗ ទៅទៀត ។

វិធីឈ្លានពានប្លន់យកទឹកដីខ្មែរ ដោយខុសច្បាប់ បានអនុវត្តន៍ សាជាថ្មីម្តងហើយម្តងទៀត នៅក្រោមរជ្ជកាលយួន មិញ ម៉ាង (Minh Mang) ។ ទាហាន "កសិករ" បានប្លន់យកទឹកដីខ្មែរមក បង្កបង្កើនផល ជាមួយគ្រួសារវារហូតដល់ ៣ឆ្នាំ ទើបបង់ពន្ធ អាករផ្ទាល់ខ្លួន ។ ក្នុងពេលចម្បាំងជាមួយខ្មែរ យួនវាបាន ប្រើច្បាប់លុកលុយរាតត្បាត និងរំលោភយកទឹកដីខ្មែរ ។

ប្រជាជនខ្មែរ បានក្រោកឡើងបះបោរប្រឆាំង និងវិធីដ៏ឃោឃៅនេះក្នុងឆ្នាំ១៨៥៦ ក្នុងឆ្នាំ១៨៥៩ និងក្នុងឆ្នាំ១៨៦១ ។ នេះជាមូលហេតុ ដែលធ្វើឲ្យយួន កាន់តែមានការសង្កត់សង្កិន ដ៏សាហាវព្រៃផ្សៃយ៉ាងក្រៃលែង ។

ពួកយួនវាក៏បានធ្វើទុក្ខបុកម្នេញដល់ ពួកកាន់សាសនាកាតូលិកផងដែរៗ ហេតុនេះបានជាមានអន្តរាគមន៍ បារាំងសែស ដែលសំរេចឲ្យមានសន្ធិសញ្ញា នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ ១៨៦២ និងថ្ងៃទី១៥ ខែមិនា ឆ្នាំ១៨៧៤ ដែលអធិរាជយួនបានប្រគល់ទឹកដីកម្ពុជាក្រោម ទៅបារាំងសែស ។

បារាំងបានទទួលស្គាល់សិទ្ធិ នឹងសេរីភាពរបស់ខ្មែរនៅកម្ពុជាក្រោម ហើយនិងធានារ៉ាប់រង នូវការផារសំខាន់ៗជាវិជ្ជមានខ្លះៗ ។

គ្រាន់តែបារាំងត្រូវយួនបណ្តេញចេញ ពីឥណ្ឌូចិនភ្លាមយួនក៏បានចាប់យក នយោបាយឈ្លានពាន ដដែលមកវិញ ។ ហេតុអ្វីបានជាយួនមានការកាប់សម្លាប់ មនុស្សដោយចេតនាយ៉ាងដូច្នេះ? អ្នកណាក៏ដឹងថា កូសាំងស៊ីនបារាំងជាដីរបស់ខ្មែរដែរ ហើយថែមទាំងបើកឲ្យយួនមករស់នៅដោយសន្តិភាព ព្រមទាំងយកស្រីយួនធ្វើជាប្រពន្ធថែមទៀត យ៉ាងនោះធ្វើឲ្យមានអាសន្ន ដោយបាត់បង់ទឹកដីនាបច្ចុប្បន្ន និងទៅអនាគត ។

ដោយយោលទៅតាមប្រវត្តិសាស្ត្រ កំដូចជាតុលាការផងដែរ កូសាំងស៊ីនជាដីរបស់ខ្មែរ យួនវាបានប្រយុទ្ធយ៉ាងស្វិតស្វាញ ដើម្បីបំបាត់វប្បធម៌ខ្មែរ ឲ្យអស់ពីទឹកដីរបស់បុព្វបុរសយើង។

នេះបានបញ្ជាក់នូវព្រឹត្តការណ៍ ក្នុងឆ្នាំ១៩៤៥ និង ឆ្នាំ១៩៤៦ ជាពិសេសប្រជាជន ដែលរស់នៅក្នុងតំបន់ ពល លាវ (Baclieu) និងទឹកខ្មៅ (Camau) ។

នៅទីនោះមានបញ្ញវ័ន្តខ្មែរ ឲ្យចូលរួមសម្ងាត់ ដើម្បីរិះរក មធ្យោបាយដ៏ស័ក្តសិទ្ធ ប្រឆាំងតទល់និងអនានិគម និយម បារាំងសែស ។

ការពិតបញ្ញាវ័ន្តខ្មែរទាំងអស់នោះ ត្រូវពួកយួនវាសម្លាប់ រង្គាលយ៉ាងសាហាវ ដោយច្រមុជក្នុងទឹកឲ្យស្លាប់ ឬដោយ មធ្យោបាយផ្សេងៗទៀត ។

នៅទីកន្លែងណាដែលមានកម្មករខ្មែរ យួនវាបានបង្ខំឲ្យប្រមូល ផ្តុំ ដើម្បីប្រមូលកម្លាំង តទល់នឹងអាណានិគមនិយមបារាំង ។ ប៉ុន្តែកសិករទាំងនោះ ត្រូវឃុំឃាំងក្នុងចង្រ្កុកស្រូវ ហើយត្រូវ

ពួកយួនវាដុតទាំងរស់ ឬខ្លះត្រូវទទួលទណ្ឌកម្ម ដោយកាត់ក មានចំនួនខ្មែរជាច្រើន ដែលត្រូវរងគ្រោះយ៉ាងវេទនាដូច្នេះ ។

ក្នុងសម័យនោះ ពួកយួនវាបានវាយប្រហា មិនតែចំពោះប្រជាជនស្លូតត្រង់ប៉ុណ្ណោះទេ មកលើសាសនាយ៉ាងព្រៃផ្សៃថែមទៀតផង ។

នេះបានបញ្ជាក់យ៉ាងច្បាស់ ដោយយួនវាធ្វើការបំផ្លេចបំផ្លាញវត្តអារាមនិងរូបបដិមាករព្រះពុទ្ធ ព្រមទាំងធ្វើឃាតព្រះសង្ឃថែមទៀត ។

នៅខែសីហា ឆ្នាំ១៩៤៥ ជ័យជំនះនៃបក្សសម្ព័ន្ធទៅលើជប៉ុន បានអនុញ្ញាតិឲ្យបារាំង យកអនានិគមខ្លួនវិញ គឺ : កូសាំងស៊ីនពីមុន ឬកម្ពុជាក្រោមសព្វថ្ងៃនេះ ។

ក្រោយពីការចរចារយ៉ាងយូរ ហើយឥតប្រយោជន៍ជាមួយយួនយៀកមិញ នៅទីក្រុងប៉ារីសនឹងក្រុងហាណូយមក បារាំងបានទាក់ទងនិងស្តេចយួន វិញធុយ (Vinh Thuy) ដែលត្រូវនិរទេសខ្លួនទៅនៅ ហុង កុង ដែលក្រោយមកក្លាយ

ទៅជាអធិរាជយួន បាវ ដាយ (Bao Dai) ដើម្បីរៀបរៀបមន្ត
សម្រុះសម្រួលឯករាជ្យជាតិ និង ការជាប់ជំពាក់បច្ច័យជាមួយ
សហភាពបារាំងសែស ។

នេះជាការសម្រេច នៃការព្រមព្រៀង នៅថ្ងៃទី៥ ខែមិថុនា
ឆ្នាំ១៩៤៨ នឹង ថ្ងៃទី៨ ខែមិនា ឆ្នាំ១៩៤៩ ដែលបញ្ជាក់ពីឯក
រាជ្យ នៃប្រទេសយួនអាណ្ណាម ក្នុងមជ្ឈដ្ឋានសហភាពបារាំង
នៅយប់ថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៤៩ សភាជាតិបានបោះ
ឆ្នោតសម្រេច ដោយភ្ជាប់កូសាំងស៊ីន ដែលជាអនានិគម
បារាំងពីមុន ទៅជាអនានិគមរបស់យួនវិញ ដោយផ្ទុយស្រ
ឡះពីឆន្ទៈរបស់ប្រជាជនខ្មែរក្រោម និងគ្មានខ្វល់ខ្វាយពីការ
តវ៉ាពីអ្វីៗ ពីព្រះមហាក្សត្រខ្មែរសោះឡើយ ។

ក្រោយមកទៀតមាន សង្គ្រាមលើកទី១ នៅឥណ្ឌូចិន
ដែលបានបញ្ចប់យ៉ាងអាម៉ាស់បំផុត ដោយបារាំងត្រូវបរាជ័យ
នៅ ឌៀន បៀនភូ (Dien Bien Phu) នៅថ្ងៃទី៧ ខែឧសភា
ឆ្នាំ១៩៥៤ ។ (ដោយនាយទាហានបារាំងសែសទាំងអស់ ត្រូវ

បាញ់សម្រាំមលើគ្រែរបស់ស្រីយួន ដែលដឹកនាំដោយ នាង មើយឡាំមួយ កញ្ញាវ័យ១៥ Sic...) ។

កិច្ចព្រមព្រៀងនៅក្រុង ហ្សឺ ណែវ (Genève) នា ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៥៤ ដែលអនុញ្ញាតិឲ្យមាន "១" សំ ខាន់ៗផ្សេងទៀតគឺ៖ ការបំបែកប្រទេសយួន ឲ្យទៅជា រដ្ឋពីរ គឺ៖

១-សាធារណរដ្ឋប្រជាធិបតេយ្យយួនខាងជើង និង

២-សាធារណរដ្ឋយួនខាងត្បូង តាមបន្ទាត់ស្របទី១៧ កងទ័ពបារាំងសែសដែលបញ្ជូនមក ត្រូវតែដកថយឥតបង្អង់ ចេញពីប្រទេសយួនខាងជើង ហើយត្រូវយកទីប្រឹក្សាទ័ព អាមេរិកកាំងមកជំនួសវិញ ។

នៅប៉ែកយួនខាងត្បូង ដោយការឡើងកាន់អំណាច ថ្មីនៃរដ្ឋការយួន ង៉ោ ឌិន យៀម (Ngo Dinh Diem) ។ ដោយដឹងថាផ្នែកខាងទក្សិណ ទីបំផុតដែលហៅថា សាធារណ រដ្ឋយួនខាងត្បូងជារបស់ខ្មែរ (កម្ពុជាក្រោម) ហើយខ្មែរ

ត្រូវមានសិទ្ធិ តវ៉ាជានិច្ចដល់រដ្ឋាភិបាល ង៉ោ ឌិន យៀម ។ ចំពោះការប្រល័យពូជសាសន៍ ដែលជនរួមជាតិយួន បានធ្វើដោយឃោឃៅ និងដោយចេតនា ព្រោះគេពុំព្រមចុះញ៉ម ដូចជាជាតិ ហ៊ីតឡើរ៍ (Hittler) ដែលធ្វើចំពោះជនជាតិ ហ្សូស (Jews) ឡើយ។

អំពើព្រៃផ្សៃរបស់យួន ដំបូងវាបានបង្កើតឲ្យមានច្បាប់មួយ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៥៦ ដើម្បីលប់បំបាត់ចោលជាតិខ្មែរ របស់ខ្មែរកម្ពុជាក្រោម ដោយបង្ខំខ្មែរឲ្យជ្រើសរើសយកជាតិយួន ដែលជាសត្រូវស្នូលពូជរបស់ខ្លួនវិញ ហេតុនេះយួនត្រូវប្តូរយកឈ្មោះខ្មែរ ទៅជាឈ្មោះយួនទៀត ។ <u>ឧទាហរណ៍</u> : ត្រា សុត ប្តូរទៅជា ត្រា ភួក គៀន ឈ្មោះ សុន យ៉ូន ទៅជា សឺង តាន់ ឡាញ់ ។ល។

បទបញ្ជាបានធ្វើនៅគ្រប់ខេត្ត និងនៅក្រសួងរដ្ឋបាលសំខាន់ៗ មិនឲ្យចេញសំបុត្រកំណើត ដល់អ្នកណាម្នាក់ដែលចង់រក្សាទុកឈ្មោះខ្មែរឡើយ ។ ខេត្តជាច្រើនដែលបំបែកជាថ្មី

ត្រូវបានទទួលឈ្មោះជាយួនៈ ហេតុនេះហើយបានជា ខេត្ត ត្រា វិញ ក្លាយជា វិញ ប៊ិញ (Vinh Binh) ស្រុក ទ្រាំង ក្លាយជា បាស្វៀន (Baxuyen) ។ល។

ហើយក៏ប្តូរឈ្មោះដូចៗគ្នាចំពោះ ភូមិស្រុកនឹងវត្តអារាមដែរ។

ពួកយួនវាបានជំរុញ នូវភាពឃោឃៅ ឥតមនុស្សធម៌ របស់វា រហូតដល់ឃាត់ឃាំង មិនឲ្យមានការសិក្សាភាសាខ្មែរ ដល់យុវជនខ្មែរកម្ពុជាក្រោម ដើម្បីបង្ខំឲ្យរៀនតែភាសាយួន ប៉ុណ្ណោះ។

នេះជាវិធានការ ដ៏ឧក្រិដ្ឋដែលវាប្រព្រឹត្ត ទៅលើប្រជាជាតិ មួយ ដែលបង្ខំឲ្យសិស្សានុសិស្សខ្មែរ ចាកចេញពីថ្នាក់ប្រឡង ដែលវិញ្ញាសារ សុទ្ធសឹងតែភាសាយួនទាំងអស់ ។

សិស្សានុសិស្សទាំងនោះ បានបញ្ចេញនូវការមិនសប្បាយចិត្ត ដល់អភិបាលខេត្តមាននៅ ស្រុក ទ្រាំង ពល លាវ ជាដើម ។

នៅពេលនោះរដ្ឋអំណាចយួន វាបានឆ្លើយតបនិងការ បង្ក្រាបយ៉ាងសាហាវបំផុត ។ ចំនួនកូនខ្មែរ ដែលនៅកម្ពុជា

ក្រោម ដែលមានអាយុពី ៦ ឆ្នាំ ដល់ ១៥ ឆ្នាំ ត្រូវបានវាបង្ខំឲ្យរៀនភាសាយួន ដែលមានចំនួនប្រហែល ១៥០.០០០ នាក់ ។

អំពើឃោរឃៅ និងអមនុស្សធម៌ របស់យួនរឹងរឹតតែមានសកម្មភាពយ៉ាងព្រៃផ្សៃ និងអយុត្តិធម៌ថែមទៀត ព្រមទាំងតទល់ប្រឆាំងនឹងសាសនាព្រះពុទ្ធ ឧបាសក ឧបាសិកា ព្រះសង្ឃ ព្រមទាំងពុទ្ធបរិស័ទទាំងអស់ ទូទាំងកម្ពុជាក្រោមទាំងមូល ។ ដោយមានគោលបំណង នឹងរំលាយពូជសាសន៍ និងព្រះពុទ្ធសាសនា ដែលវាគិតថា៖ ជាមូលដ្ឋាន នៃវប្បធម៌របស់បុព្វបុរសយើង ។

រដ្ឋអំណាចនៅព្រៃនគរ បានតែងតាំង ហ៊ុយ វ៉ាន់ដាត់ "Huynh Van Dat" ជាសង្ឃរាជ លើព្រះសង្ឃខ្មែរទាំងអស់ ហើយបានបង្កើត ពុទ្ធកវិទ្យាស្ថានជាន់ខ្ពស់មួយ ដែលគេប្រើតែភាសាយួន ប្រវត្តិសាស្ត្រយួន ការបង្រៀននេះ ព្រះធម៌ និងបាលី នៅក្រោមការត្រួតត្រា របស់ព្រះសង្ឃរាជយួន ដូចបានជំរាបមកហើយ ។

ព្រះសង្ឃខ្មែរ ដែលចេញពីវិទ្យាស្ថាននេះ បានត្រូវតែងតាំងជាគ្រូឧប្បជ្ឈាយ៍ ហើយបញ្ជូនទៅតាមខេត្តនានា ដើម្បីបង្រៀនព្រះធម៌ តាមរបៀបយួនទាំងអស់ ។

គណកម្មាធិការ សមាគមព្រះពុទ្ធសាសនា នៅកម្ពុជាក្រោម ត្រូវបានរំលាយចោល ។ ការចាត់ចែងបុណ្យទាន សាសនា ត្រូវបានហាមឃាត់ ។ ព្រះសង្ឃខ្មែរពុំមានសិទ្ធិ សូត្រធម៌ជាភាសាខ្មែរ នៅចំពោះមុខពុទ្ធបរិស័ទឡើយ នេះជាការរំលោភពេញទី ចំពោះសិទ្ធិមនុស្ស ។

ដោយឆ្លៀតឱកាសធ្វើសង្គ្រាម ជាមួយនឹងពួកកុម្មុនិស រដ្ឋអំណាចយួននៅព្រៃនគរ បានទំលាក់គ្រាប់បែកទៅលើវត្តអារាមខ្មែរ ដោយយកលេសថា ខ្មែរឲ្យពួកយៀកកុងជ្រកនៅ ហើយសម្លាប់រង្គាលព្រះសង្ឃ និងពុទ្ធបរិស័ទ ដែលរត់ទៅរកទីជំរកក្នុងគ្រាអាសន្ន ។ យោងតាមស្ថិតិ ដែលផ្ដល់មកពីរណសិរ្ស ប្រយុទ្ធនៃកងកម្លាំងកម្ពុជាក្រោម បានឲ្យដឹងថា៖

ចំនួនកុដិ និងវត្តអារាម ដែលបំផ្លាញដោយ រដ្ឋអំណាចយួន

នៅព្រៃនគរ ក្នុងថ្ងៃមហាសន្និបាត នៃប្រជាជនឥណ្ឌូចិន នាខែមិនា ឆ្នាំ១៩៦៥ មាន ចំនួនទាំងអស់ ១២៤ លើចំនួនវត្ត ៦៣០ ដែលមានដូចតទៅ ៖

| | |
|---|---|
| ក្នុងខេត្ត ត្រា វិញ | ២៤ វត្ត |
| ក្នុងខេត្ត ឃ្លាំង | ១៤ វត្ត |
| ក្នុងខេត្ត ពល លាវ | ១០ វត្ត |
| ក្នុងខេត្ត ព្រែកឬស្សី | ៧ វត្ត |
| ក្នុងខេត្ត មាត់ជ្រូក | ១៨ វត្ត |
| ក្នុងខេត្ត ក្រមួន ស | ១៨ វត្ត |
| ក្នុងខេត្ត ពោធិ៍សាត់ | ២៨ វត្ត |
| ក្នុងខេត្ត ហា ទៀង | ២ វត្ត |
| ក្នុងខេត្ត យ៉ា ឌិញ | ១ វត្ត |
| ក្នុងខេត្ត ទឹកខ្មៅ | ២ វត្ត |

---

| | |
|---|---|
| បូកសារុប | ១២៤ វត្ត |

រីឯវត្តដែលគ្មានទទួល នូវការរង់គ្រោះវិញ ព្រះសង្ឃពុំអាចគង់នៅបាន ដោយសុខសាន្តទេ ។ រដ្ឋអំណាចយួននៅព្រៃនគរ បានបង្ខំឲ្យព្រះសង្ឃចាកសិក្ខាបទ ដើម្បីឲ្យចុះឈ្មោះធ្វើជាទាហាន ដោយបង្ខិតបង្ខំជាទីបំផុត ។ បើអ្នកណាហ៊ានប្រឆាំង និងត្រូវជាប់គុក ហើយធ្វើទារុណកម្មយ៉ាងខ្លោចផ្សា ។ បើអ្នកណាស្នេហាជាតិ ស្នេហាមាតុភូមិរបស់ខ្លួន ត្រូវជាប់ចោទពីបទ យប់ឃិត ជាមួយពួកយៀក កុង អ្នកទាំងនោះត្រូវសម្លាប់ដោយព្យាបាទ ដូចជាព្រះតេជគុណ កែ អាង នៅវត្តឃ្លាំង នឹងព្រះតេជគុណ កុល ប៉ុន នៅវត្តស្វាយ ទង ដែលត្រូវធ្វើឃាដ គួរឲ្យសោកស្ដាយជាទីបំផុត ។

ចំណែកប្រជាជនស៊ីវិលវិញ ក៏បានពើបប្រទះនិងព្រឹត្តការណ៍ភ័យអាសន្ននេះដែរ ហើយធ្លាក់ខ្លួនក្នុងស្ថានភាពតឹងតែងថែមទៀតផង ។

«ហេតុនេះគឺយួនតែមួយ» ដែលមានគំនិតប្រឆាំង បានអនុវត្តន៍ នយោបាយប្រល័យពូជសាសន៍ដូចៗគ្នា ទៅលើសហ

គមន៍ ខ្មែរកម្ពុជាក្រោមយ៉ាងសែនឃោរឃៅរកអ្វីប្រៀបគ្មាន ។

ចំពោះភ្នែកពិភពលោក ពួកយួនដែលនិយមខាងសេរី បាននាំគ្នាប្រឆាំងតទល់យ៉ាងខ្លាំង និងរណសិរ្សរំដោះជាតិខ្មែរកម្ពុជាក្រោម នៅយួនខាងត្បូង ។

តាមពិតស័ព្វទាំងសងខាង ទាំងយួនកុម្មុនិស្ត ទាំងយួនសេរី បានប្រើគ្រប់មធ្យោបាយ ដើម្បីជាន់ឈ្លីលើសិទ្ធិ និងសេរីភាពសំខាន់ៗ របស់ខ្មែរកម្ពុជាក្រោមទៅវិញទេ ។

ចំណែកអ្នកស្រែចំការយើង បានត្រូវវាបង្ខំឲ្យរស់នៅ ក្នុងភូមិដាច់ស្រយាល ការពារដោយខ្សែលួសបន្លា និងរណ្តៅធំៗ ប៉ុណ្ណោះ ។ ដីធ្លីខ្មែរត្រូវរដ្ឋអំណាចយួន វារិបអូសយកអស់ ហើយពួកវាយកទៅ ចែកចាយដល់ពួកជន ភៀសខ្លួនវាមកពីតុង កឹង ។ អ្នកប្រឆាំងជំទាស់ ត្រូវចាប់ឃុំឃាំង ហើយធ្វើទារុណកម្មយ៉ាងវេទនាក្នុងករណីខ្លះត្រូវសម្លាប់ចោលទៀតផង។ ចំណែកយុវជនខ្មែរកម្ពុជាក្រោម ត្រូវវាចាប់ចូលធ្វើទាហាន ។ រីឯចាស់ៗ ត្រូវបង្ខំឲ្យធ្វើការ ទាំងយប់ទាំងថ្ងៃ ហើយត្រូវធ្មៀត

យកពេលវេលា ធ្វើការដើម្បីរកគ្រឿង ចិញ្ចឹមជីវិតផ្ទាល់ខ្លួន ។ ខ្មែរជាច្រើននឿយហត់យ៉ាងខ្លាំង ហើយស្លាប់ក្នុងពេលធ្វើការកំណែនដោយលំបាក ។

ម្យ៉ាងវិញទៀត ក្រៅពីសេចក្តីទុក្ខវេទនា ឈឺចាប់យ៉ាងខ្លាំងខាងផ្លូវកាយ គ្រួសារខ្មែរកម្ពុជាក្រោម ត្រូវបង់វិភាគទានដើម្បីបំរើដល់ទាហាន បដិបក្ខទាំងពីរ ហើយដើម្បីបំប៉នទាហានទាំងនោះ ឲ្យមកជិះជាន់ សង្កត់សង្កិនខ្មែរកម្ពុជាក្រោមថែមទៀត ។ បញ្ញាវ័ន្តខ្មែរកម្ពុជាក្រោម អ្នកជាតិនិយម ដែលបានបំរើផលប្រយោជន៍ខ្មែរ ទោះត្រូវយួនវាសម្លាប់ដោយគ្រាប់បែក, ដោយគ្រាប់កាំភ្លើង ឬដោយកាំបិតស្នៀតក្តី ក៏ខ្មែរក្រោមនៅតែធ្វើការតស៊ូ ការពារជាតិខ្លួននិងទឹកដីជានិច្ច ។ អ្នកឯទៀតត្រូវពួកកនវា យកទៅកាត់ក វះពោះទម្លាក់ក្នុងទឹកទាំងរស់ ដោយចងដៃចងជើង ប្រសិនបើមិនដុតទាំងរស់ក្នុងបន្ទប់សម្ងាត់របស់ពួកកនវាទេ ។

ពួកអាហ្វាស៊ីសយុងយ្ហងទាំងនេះ បានធ្វើរហូតដល់បំពុលប្រ

ជាជនខ្មែរក្នុងភូមិ ដោយប្រើថ្នាំបំពុលជាតិគីមី របស់កងទ័ព ឧក្រិដ្ឋវា ។

ចាប់តាំងពីចម្បាំងលោកលើកទី២ ដំបូងនៅឥណ្ឌូចិន ខ្មែររាប់ម៉ឺន រាប់សែននាក់ត្រូវវាសម្លាប់ ដោយអំពើដ៏កំសាក នេះ វត្តអារាមរាប់រយត្រូវបំផ្លាញ ផ្ទះសម្បែងរាប់ម៉ឺនត្រូវដុត បំផ្លាញចោល ដំណាំដាំដុះត្រូវវាបំផ្លាញឲ្យហិនហោច របស់ ទ្រព្យត្រូវបាត់បង់ ដីធ្លីជាច្រើនហិកតា ក្លាយជាទីរហោស្ថាន ឬ ត្រូវយួនវារឹបយក ។

ចង្រៃជាងនេះទៅទៀត ពួកទាហានយួនបដិបក្ខ វាទាស់ ទែងគ្នាអំពីជណ្តើមសិទ្ធ កែនខ្មែរកម្ពុជាក្រោម មានព្រះសង្ឃ ពុទ្ធបរិស័ទ មនុស្សចាស់ ស្ត្រី និងក្មេង ដើម្បីសម្តែងការប្រ ឆាំងទាំងសងខាង ជួនកាលប្រឆាំង និងជនរួមឈាមកម្ពុជា ហើយច្រើនតែប្រឆាំង តទល់និងប្រមុខរដ្ឋខ្មែរ ដែលគេគោរព ទាំងអស់ ។

ក្រៅពីពួកខ្មែរក្បត់ជាតិមួយក្តាប់តូចនេះ ខ្មែរដែលលក់

ខ្លួនឲ្យពួកអាយ៉ងយួនព្រៃនគរ នឹងយួនហាណូយគ្មានខ្មែរណាម្នាក់មានគំនិតប្រឆាំងតទល់ និងប្រមុខរដ្ឋខ្មែរ ដែលប្រជាជនព្រមទាំងរដ្ឋាភិបាលជាទីស្រឡាញ់នោះទេ ។

ខ្មែរកម្ពុជាក្រោមរាប់ម៉ឺនគ្រួសារ ដែលបានរត់គេចចេញ អំពីការរិះបជាន់ជិះសាហាវ នៃអាយ៉ងយួន ដើម្បីទៅជ្រកកោណនៅមាតុប្រទេសជាតិ ជាពិសេសក្នុងឆ្នាំ ១៩៦០-១៩៦១ ក្នុងគោលបំណង និងបានស្គាល់ភាពស្ងប់ស្ងៀម និងសេរីភាពក្នុងការរស់នៅ នៃការគ្រប់គ្រងដោយគន្លងធម៌ និងដោយសប្បុរសរបស់សម្តេច នរោត្តមសីហនុ ហើយភាពចំរុងចំរើននៃកោះសន្តិភាព ជាសក្តីភាពប្រសើរបំផុត សក្តីភាពនៃការពិត និងសក្តីភាពនៃការជាប់ជំពាក់ចិត្តពិតៗ ទៅនិងកម្ពុជា និង អ្នកដឹកនាំជាទីស្រឡាញ់ ។

ការខូចខាតជីវិតមនុស្ស និងភោគទ្រព្យដែលខ្មែរកម្ពុជាក្រោម បានទទួលរងគ្រោះ ដោយពួកយួន មានដូចតទៅនេះ ៖

## ជនស៊ីវិល

| ស្លាប់ | របួស | ជាប់គុក | បាត់ខ្លួន | ភៀសខ្លួន |
|---|---|---|---|---|
| ៦.២១៦ | ២៤.៥៦០ | ៣៥.៤១២ | ៣.០១៨ | ១១៥.២៥០ |

## បុព្វជិត

| ស្លាប់ | របួស | ជាប់គុក | បាត់ខ្លួន | ភៀសខ្លួន |
|---|---|---|---|---|
| ៣០០ | ៥០៥ | ១០៦ | ២៥ | ៥.០១៥ |

## ផ្ទះសម្បែងខូចខាត

| | | |
|---|---|---|
| ក្នុងខេត្ត មាត់ជ្រូក | ផ្ទះចំនួន | ៥.១៥៦ ខ្នង |
| ក្នុងខេត្ត ព្រះត្រពាំង | ផ្ទះចំនួន | ២១.៥០០ ខ្នង |
| ពល លាវ | ផ្ទះចំនួន | ១០.២៤០ ខ្នង |
| ក្រមួនស | ផ្ទះចំនួន | ១៥.៨០០ ខ្នង |
| ព្រែកឫស្សី | ផ្ទះចំនួន | ៧.៥៣០ ខ្នង |
| ឃ្លាំង | ផ្ទះចំនួន | ១៥.៣០០ ខ្នង |
| ឡុង ស៊ុយយេន | ផ្ទះចំនួន | ១.២០០ ខ្នង |

| | | |
|---|---|---|
| ទឹកខ្មៅ | ផ្ទះចំនួន | ៥.២០០ ខ្នង |
| ពោងដីរ | ផ្ទះចំនួន | ២១.០០០ ខ្នង |

# ៤

## ការតស៊ូប្រឆាំងរបស់ខ្មែរក្រោម

ទោះបីមានការបញ្ចូលជាតិខ្មែរ ឲ្យទៅជាជនជាតិយួន និង មានការប្រល័យពូជសាសន៍ ប្រព្រឹត្តដោយពួកយួន តទល់និងខ្មែរក៏ដោយ ក៏ខ្មែរកម្ពុជាក្រោម នៅមានចំនួន ពីរលានប្រាំមួយសែននាក់ទៀត គឺៈ ព្រះសង្ឃ, អ្នករាជការ, ទាហាន, និស្សិត, ពាណិជ្ជករ និងកសិករ ។ល។

ប្រសិនបើ ប្រជាជនខ្មែរកម្ពុជាក្រោម ចំនួនពីរលានប្រាំមួយ សែននេះ អាចរួចរស់រានមានជីវិត ផុតពីការសម្លាប់រង្គាល របស់ពួកយួននោះ មូលហេតុមកពី ការតស៊ូប្រឆាំង ឥតឈប់ឈរ មកពីប្រតិសកម្ម និងការតស៊ូដ៏ក្លាហាន របស់ខ្មែរកម្ពុជាក្រោមតទល់ និងពួកយួនលុកលុយឈ្លានពាន ។

ខ្មែរកម្ពុជាក្រោម មានគុណសម្បត្តិល្អ សុចរិត ស្មោះត្រង់ ស្រឡាញ់សន្តិភាព នឹងក្លាហានដូចប្រជាជនកម្ពុជា ទាំងអស់ដែរ ។

ហេតុដូច្នេះ មានបារាំង អាមេរិកកាំង ព្រមទាំងពួកយួនផងដែរ បានទទួលស្គាល់ខ្មែរកម្ពុជាក្រោម ជាអ្នកចម្បាំងដ៏ក្លាហាន នឹងអ្នកស្នេហាជាតិដ៏ក្លៀវក្លា ប្តេជ្ញាចិត្តឥតរុញរា ទោះបីត្រូវស្លាប់ក៏ដោយ ដើម្បីរក្សាទឹកដីពីបុព្វបុរស នឹងលក្ខណៈជាតិឥតសៅហ្មងក្នុងចិត្តឡើយ ។

## ក- រណសិរ្សតស៊ូរបស់ខ្មែរកម្ពុជាក្រោម

ខ្មែរកម្ពុជាក្រោម បានរត់ចូលព្រៃ ហើយបង្កើតរណៈសិរ្សតស៊ូរបស់ខ្មែរកម្ពុជាក្រោម ។

គោលដៅសំខាន់របស់ខ្មែរកម្ពុជាក្រោម គឺៈវាយដណ្តើមយកសិទ្ធិសេរីភាព របស់ខ្មែរកម្ពុជាក្រោមមករៀបចំ ដោយឯករាជ

ម្ចាស់ការខ្លួនឯងវិញ ។

ខ្មែរកម្ពុជាក្រោមទាំងអស់ បាននាំគ្នាប្រយុទ្ធយ៉ាងស្វិតស្វាញ ជាមួយពួកយួនយៀក កុង យៀក ណាមខាងត្បូង ។

ដើម្បីធ្វើឲ្យការតស៊ូ របស់ខ្មែរកម្ពុជាក្រោម ឱយកាន់តែទូលំទូលាយ និងមានប្រសិទ្ធិភាពឡើង ខ្មែរកម្ពុជាក្រោម បានរួបរួមជាមួយមិត្ត នៅលើកំពូលភ្នំ និងទីវាលរាបនៃប្រទេសចម្ប៉ា ក្នុងអង្គការមួយហៅថា៖

" រណសិរ្សរួបរួមប្រឆាំង និង សាសន៍ដែលជិះជាន់គេ "

(F.U.L.R.O.) ដែលប្រជុំគ្នាធ្វើច្បាប់ ពិសិដ្ឋជាម្ចាស់ទឹកដីពីបុព្វបុរសគេ ដែលមានចំណងជើងដូចជា អង្គការស្នេហាជាតិនៅឥណ្ឌូចិនដែរ ។

នៅខែកុម្ភៈ ១៩៦៥ អង្គការនោះត្រូវគណបក្ស សង្គមរាស្រ្តនិយម អញ្ជើញទៅរួមប្រជុំ ក្នុងមហាសន្និបាទ ប្រជាជនឥណ្ឌូចិន Conférence des Peuples Indochinois (C.P.I.) ។

នៅខែសីហា ឆ្នាំ១៩៦៨ គណប្រតិភូយោធានៃរណៈសិរ្សតស៊ូខ្មែរកម្ពុជាក្រោម (F.L.K.K.) បានមកដល់ មីថួត (Mithour) ជាមួយនិងគណៈប្រតិភូ រណៈសិរ្សរំដោះលើខ្ពង់រាបភ្នំ និងដីរាបនៃប្រទេសចម្ប៉ា ដើម្បីពិភាក្សាជាមួយរដ្ឋអំណាចព្រៃនគរ អំពីបញ្ហារួមៗ ការពិភាក្សាពុំបានសម្រេចទេ ពីព្រោះរដ្ឋអំណាចព្រៃនគរ ពុំព្រមទទួលស្គាល់ខ្មែរកម្ពុជាក្រោម ជាប្រជាជាតិខ្មែរទេ ហើយគេចាត់ទុកខ្មែរកម្ពុជាក្រោមដូចជាជនជាតិយួនសុទ្ធសាធទៅវិញ ។

រណៈសិរ្សតស៊ូ នៅកម្ពុជាក្រោម ក៏បន្តសកម្មភាពទៀត ។

## ១- អំពីបាតុកម្ម៖

រដ្ឋធម្មនុញ្ញនៃប្រទេសយួនខាងត្បូង និងលិខិតរបស់ (F.N.L.) ប្រមានច្បាប់ សម្រាប់ជនជាតិភាគតិច ។

ខ្មែរកម្ពុជាក្រោម ដែលអ្នកស្រឡាញ់សន្តិភាព បានប្រព្រឹត្តតាមជានិច្ច ដើម្បីអភិវឌ្ឍន៍ និង ចាត់ចែងដោយទទួលស្គាល់

រដ្ឋអំណាច ដែលគេបានសហការ ក្នុងក្របខ័ណ្ឌរដ្ឋការ និងទាហាន ។ នៅក្នុងភូមិខ្មែរកម្ពុជាក្រោម យើងបានតែងតាំង គណៈកម្មាធិការ ដើម្បីតទល់ និងពួកយួនយៀកកុង ។ លោករដ្ឋមន្ត្រីនៃសហរដ្ឋអាមេរិក ឌីន រ៉ាស្ស៊ក៍ ( Dean Rusk ) បានប្រកាសថា៖ "គឺសុទ្ធតែទាហានខ្មែរកម្ពុជាក្រោមទេ ដែលជាយុទ្ធជនអង់អាចក្លាហាន ដ៏ល្អប្រសើរណាស់ នៅប្រទេសយួនខាងត្បូង "។

រដ្ឋអំណាចយួនខាងត្បូង គួរតែទទួលស្គាល់ការរួមរស់ជាមួយគ្នា ប៉ុន្តែផ្ទុយទៅវិញពួកយួនខាងត្បូង បែរជាទៅត្រូវរូវជាមួយពួកយួនយៀកកុងទៅវិញ ដោយបោកប្រាសសហរដ្ឋអាមេរិក ដើម្បីសម្លាប់ខ្មែរកម្ពុជាក្រោម ឲ្យផុតពូជ ។

អ្នកស្រែចំការខ្មែរយើង ឃើញតែឈ្មោះយួនជាញឹកញាប់ក្នុងបញ្ជីសង្ហារិមវត្ថុ ជំនួសឈ្មោះខ្លួនទៅវិញ ។ ចំណែករដ្ឋការ និងទាហានខ្មែរ បានត្រូវចាត់ឲ្យទៅធ្វើការ នៅកន្លែងមានគ្រោះថ្នាក់មុនគេ ហើយលំដាប់ស័ក្តក៏ឡើងយឺតជាងសហ

ការីយួនទៅវិញ ។ មធ្យោបាយនៃការអភិវឌ្ឍន៍ អំពើផុយ ដើម្បីឲ្យសិទ្ធ ទៅដល់អ្នកនិន្នាការបំរើយួនមុនគេ ។ ដើម្បីដាក់អំពើប្រល័យពូជសាសន៍ ឲ្យស្របច្បាប់ និងលាក់បំបាំង នូវការប្រកាន់ពូជសាសន៍ ។

រដ្ឋអំណាចយួនព្រៃនគរ មិនរុញរា និងប្រកាសជាផ្លូវការ នៅខែកញ្ញា ១៩៦៩ ថា៖ ខ្មែរកម្ពុជាក្រោម បានវិវត្តយ៉ាងខ្លាំង ដើម្បីប្រមូលផ្តុំជនជាតិភាគតិច ហើយខ្មែរកម្ពុជាក្រោម ជាពលរដ្ឋយួនសុទ្ធសាធ ដូចជាជនជាតិយួនដែរ ។

ដោយបានរៀនសូត្រ និងដកពិសោធន៍យ៉ាងនេះទើបខ្មែរកម្ពុជាក្រោម បានស្គាល់នូវគំនិត និងនយោបាយដ៏ខ្មៅក្រខ្វក់របស់ពួកយួន ឃើញយ៉ាងជាក់ច្បាស់ថា៖

នេះជា "យន្តបនិយកម្ម" សុទ្ធសាធ (Annamesesation) ដូច្នេះ ខ្មែរកម្ពុជាក្រោម បាននាំគ្នាតវ៉ា យ៉ាងម៉ឺងម៉ាត់ដល់រដ្ឋអំណាចព្រៃនគរ ហើយបានសុំឲ្យទទួលស្គាល់ ខ្មែរកម្ពុជាក្រោម ដូចជាជនជាតិភាគតិចផ្សេងៗទៀត (នៅយួនកណ្តាល) ។

បន្ទាប់ពីការទាត់ចោលនូវបណ្តឹង ជាលាយលក្ខណ៍អក្សរ ត្រឹមត្រូវនិងពេញច្បាប់មក ខ្មែរកម្ពុជាក្រោម បានបញ្ជូនអ្នកតំណាង របស់ខ្មែរកម្ពុជាក្រោម ទៅខេត្ត កាន់ ថូ (Cantho) និង ព្រៃនគរ ក្នុងគោលបំណង និងបង្កើតអង្គការ ខ្មែរកម្ពុជាក្រោម ដែលមានបេសកកម្ម និងទាមទារសិទ្ធ នៃលក្ខន្តិកៈ ជនជាតិភាគតិច ដល់ខ្មែរកម្ពុជាក្រោម ។

អង្គការនេះមាន គណៈកម្មាធិការកណ្តាល នៅព្រៃនគរ និង គណៈកម្មាធិការ នៅតាមខេត្តនានា ។

ដែលរដ្ឋអំណាចយួនព្រៃនគរ បានទទួលបណ្តឹងជារឿយៗ ។

ដោយយល់ច្បាស់ពីសិទ្ធរបស់ខ្លួន អ្នកដឹកនាំគណៈកម្មាធិការ ទាមទារលក្ខន្តិកៈ សម្រាប់ជនជាតិភាគតិច ប្រាប់ឲ្យដឹងជាមុននូវ សកម្មភាពរបស់គេដល់ប្រធានសាធារណរដ្ឋយួនទាំងអស់ មាន៖

រដ្ឋសភា, នាយករដ្ឋមន្ត្រី, ដោយការសន្ទនា ពិភាក្សាក្តី, ដោយលិខិតបណ្តឹងក្តី ឬដោយពត៌មាន ផ្សាយជាផ្លូវការក្តី ។

ដោយពុំអាចណែនាំ រដ្ឋាភិបាល ធីវ (Thieu) និងបក្សពួក របស់គេ ឲ្យមានវិចារណញាណបានឡើយ ខ្មែរកម្ពុជាក្រោម ក៏សំរេចធ្វើបាតុកម្ម ។

ព្រះសង្ឃបានចាប់ផ្ដើមធ្វើមុនគេ ព្រោះព្រះសង្ឃជាសញ្ញា ចរិត លក្ខណៈជាតិខ្មែរសុទ្ធសាធ ។

នៅត្រា វិញ (Travinh) ជាខេត្ត ដែលខ្មែរមានចំនួនច្រើន ហើយនៅថ្ងៃបុណ្យភ្ជុំបិណ្ឌ (ថ្ងៃទី១៣ តុលា១៩៦៩ ) ព្រះសង្ឃ ចំនួន ៨០០ អង្គ បានធ្វើបាតុកម្មនៅមុខមន្ទីរ សាលាខេត្ត ។ ព្រះសង្ឃបានប្រគល់ញត្តិតវ៉ា ស្ដីអំពី លក្ខន្តិកៈ របស់ជនជាតិ ភាគតិច ដល់ចៅហ្វាយខេត្តនេះ ហើយសំណូមពរឲ្យឆ្លើយ តបវិញក្នុងរវាង ១ ខែ ។

រដ្ឋអំណាចយួនព្រៃនគរពុំបានឆ្លើយតបទេ។ នៅថ្ងៃទី១៣ វិច្ឆិកា ឆ្នាំ១៩៦៩ ព្រះសង្ឃចំនួន ៥០អង្គ នៅព្រៃនគរ និង ២០០អង្គ ទៀតតំណាងពីខេត្តនានា បានធ្វើបាតុកម្មពីព្រលឹម នៅមុខវិមានរបស់ ធីវ (Thieu) នៅព្រៃនគរ ។

ក្នុងពេល ៥ ថ្ងៃ និង ៥ យប់ បន្តបន្ទាប់ ព្រះសង្ឃទាំងអស់ ពុំបានធ្វើឲ្យប្រធានសាធារណៈរដ្ឋយួន ង្វៀង វ៉ាន់ ធីវ ( Nguyen Van Thieu ) យល់ព្រមសោះឡើយ ។

នៅចុងថ្ងៃទី៥ ពេលអាធ្រាត្រ ស្រាប់តែមានរថយន្តកាមីយ៉ុងចំនួន១០គ្រឿង និងទាហានរាប់ពាន់នាក់ ប្រដាប់ដោយអាវុធមកដោយរួសរាន់ បញ្ឈប់បាតុករដែលកំពុងអង្គុយ ។

លុះបានហាមឃាត់ ប្រជាជនដែលរស់នៅជិតខាង មិនឲ្យមកកាន់វិថីនេះ និងហាមឃាត់អ្នកសារពត៌មាន កាសែតមិនឲ្យចូលមកជិត ពួកទាហាន ង្វៀង វ៉ាន់ ធីវ បានបញ្ឆាំងភ្លើងគោម(ហ្វា) ឲ្យខ្មែរបាតុករព្រិលភ្នែក ហើយក៏ចាប់យកបាតុករទាំងនោះ ដាក់ក្នុងរថយន្តដោយបង្ខំ ហើយដឹកទៅវត្ត ច័ន្ទរង្សី ដែលពួកវា យកទៅទម្លាក់ចោល យ៉ាងរាយប៉ាយដូចសត្វធាតុ។

នៅទីវត្តអារាមនោះ ដែលជាមជ្ឈមណ្ឌល របស់ព្រះសង្ឃខ្មែរកម្ពុជាក្រោម បានក្លាយទៅជាទីឃុំឃាំង(គុក)សំរាប់

ផ្ទាញ់ផ្ទាល របស់រដ្ឋអំណាច ធីវ ទៅវិញ ។

ការចេញចូលត្រូវហាមឃាត់ ដោយមានរថយន្តកាមីយ៉ុងពីរ គ្រឿងប្រចាំការណ៍ វត្តនេះមានរបងឈើ និងខ្សែលួសបន្លា ព័ទ្ធជុំវិញ ព្រមទាំងត្រូវយាមដោយ ពួកប៉ូលីសរាប់រយនាក់ ប្រដាប់ដោយអាវុធថែមទៀតផង ហើយមានគ្រប់មធ្យោបាយ និងធ្វើអន្តរាគមន៍ ដល់រដ្ឋអំណាចថ្នាក់លើ ។

ប៉ុន្តែក្នុងចំណោមបាតុករ មានព្រះសង្ឃចំនួន ២៥០អង្គ ដែល មានខ្វះឈឺចាប់ នឹងអំពើយុងឃ្នងនេះ ក៏បានបញ្ឈប់ធ្វើ បាតុកម្មទៅ។

គ្មាននណាម្នាក់ ត្រូវអនុញ្ញាត្តិឲ្យមើល ទៅខាងក្រៅឡើយ។ រដ្ឋការយួនស្មានថា៖ អាចលាក់បាំង កលល្បិចរបស់វា បាន ពីភ្នែកពិភពលោក ។

អំពើរបស់ពួកយួននេះធ្វើ បានបង្កើនកំហឹងនិងការក្រេវក្រោធ រឹតតែខ្លាំងឡើងៗ ដល់ប្រជាជនខ្មែរកម្ពុជាក្រោម ពីរលានប្រាំ មួយសែននាក់ និងខ្មែរទូទៅព្រមទាំង ប្រជាជនដែលស្នេហា

យុត្តិធម៌ និងគោរពសិទ្ធិមនុស្ស ។

ដើម្បីបំផ្លាញវត្តអារាម និងបញ្ចប់បាតុកម្ម ដែលមានលក្ខណៈ សន្តិភាព ភាពពេញច្បាប់ និងជាទោសកម្មដែលមានរបស់រដ្ឋាភិបាល ធីវ មកលើបាតុករខ្មែរកម្ពុជាក្រោម ។ រដ្ឋអំណាចព្រៃនគរ បានផ្តល់ពត៌មានដល់អាមេរិកកាំងថា ៖ "ជាការប្រមូលផ្តុំទ័ពសំខាន់ៗ របស់ពួកវៀតកុង ដែលកំណត់ទីតាំងនៅក្នុងវត្តចន្ទរង្សី " ។ ភ្នាក់ងារអាមេរិកកាំង (C.I.A.) បានធ្វើការស៊ើបអង្កេត ហើយដោយសំណាងល្អ បានរកឃើញនូវការពិត ។

ដោយដឹងនឹងបំរុងទុកជាមុន នូវប្រតិកម្មយ៉ាងសាហាវរបស់ ង្វៀងវ៉ាន់ ធីវ និងអ្នកគាំទ្ររបស់វា ព្រះសង្ឃខ្មែរកម្ពុជាក្រោម បានចាត់ចែងដោយ សន្តិវិធីនូវបាតុកម្មមួយទៀត ដោយផ្អែកទៅលើ បាតុកម្មនៅព្រៃនគរ ។ នៅ ត្រា វិញ, ចូវ ដុក, កាន់ ថូ, បាក់ លីវ, និង សុក ត្រាំង ដែលមាន ប្រជាជនខ្មែរកម្ពុជាក្រោម ភាគច្រើនជាងគេ

គេឃើញអ្នកទាំងនោះ នាំគ្នាដើរដង្ហែរជាក្បួនសឹក នៅមុខសាលាខេត្ត តវ៉ាអំពីលក្ខន្តិកៈ ជាតិខ្មែរនៅលើដែនដីខ្មែរ ។ នៅសុក ត្រាង ជាអាទ៍ ព្រះសង្ឃរាប់ពាន់អង្គ បានធ្វើបាតុកម្មព័ទ្ធជុំវិញ ដោយប្រជាជនខ្មែរកម្ពុជាក្រោម ដោយប្រជាប់ទៅដោយដំបង កណ្តៀវ និងដោយស្ម័គ្រចិត្ត មកពីគ្រប់ខេត្ត ។ រដ្ឋអំណាចយួនដែលបានដឹង អំពីរឿងនេះមុន បានត្រូវទទួលបាតុករទាំងនោះ ដោយរាក់ទាក់ និងគួសម ហើយសន្យាថានិងយកបញ្ហានេះ ទៅដោះស្រាយជាមួយ ប្រធានយួន ធីវ ។

ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៦៩ អស់អំឡុង ១ខែក្រោយមក " ថ្ងៃដែលជួបជុំ នៅវិមានប្រធានាធិបតី យួន" ខ្មែរបាតុករនៅព្រៃនគរចំនួន ២៥០នាក់ បានសំរុកចូលជាថ្មី ទៅក្នុងវិមានរបស់ ធីវ ដែលមានជញ្ជាំងការពារ ដោយក្រុមសន្តិសុខ និងក្រុមប៉ូលីសយួន ។

ក្រុមប៉ូលីសយួនទាំងនោះ បានវាយបាតុករខ្មែរ ដោយដំបងព្រនង់ ដោយគុបគ្រាប់បែកដៃ ដែលមានជាតិពុលនិងបាញ់

ទឹកថ្នាំពុល ។

ពួកវាថែមទាំងផ្ញើ ទុកបុកម្ទេញ ដល់ពួកអ្នកកាសែត និងបរទេស ដែលពិនិត្យសង្កេត នូវព្រឹត្តិការណ៍ពេលនោះផងដែរ ។ អ្នកកាសែតម្នាក់ត្រូវរបួស ដោយបាក់ឆ្អឹងជំនី ។ ព្រះសង្ឃ ៩អង្គ ត្រូវរបួសជាទម្ងន់ ហើយ៣១អង្គទៀត ត្រូវរបួសអាចព្យាបាលបាន ។ គេបានចាប់ប៉ូលីសឃុនជាចំណាប់ខ្មាំង ។

បាតុករខ្មែរកម្ពុជាក្រោម ទាំង២៥០នាក់បានសម្រេចចិត្ត និងស្លាប់ដើម្បីលក្ខន្តិកៈនេះ ដែលជាសិទ្ធរបស់ខ្មែរកម្ពុជាក្រោម ហើយលក្ខន្តិកៈនេះ ក៏ត្រូវបានអនុគ្រោះដល់ជនជាតិភាគតិចឯទៀតៗផងដែរ ។

លោក ឡាំ អែម ជាមេដឹកនាំព្រឹត្តិការណ៍នេះ បានរៀបចំក្លាម្សួសគាត់រួចជាស្រេច ។

គាត់មានសំណូមពរតែមួយថា សាកសពរបស់គាត់ ត្រូវយកទៅដំកល់នៅ ចំមុខវិមាន ធីវ លុះត្រាតែ ធីវ នេះយល់ព្រមប្រគល់ឲ្យ លក្ខន្តិកៈ សម្រាប់ជនជាតិខ្មែរ និង ប្រជាជនខ្មែរកម្ពុជាក្រោមចំនួន ៤,៦០០,០០០ នាក់ នៅជាខ្មែរ ។

ក្រុមបាតុករដឹងថា ប្រជាជនខ្មែរកម្ពុជាក្រោម ទាំង ៤.៦០០.០០០ នាក់ មាន ស៊ីវិល, ទាហាន, វេជ្ជការ, និស្សិត, កម្មករ និងកសិករ ។
ម្យ៉ាងទៀត ជនជាតិភាគតិចឯទៀតៗដូចជា ចាម, ហារ៉េ, រដេ, ប្រាយ, ជ្រូ, រ៉ាក្លាយ, ចោមា៉, ពីស, ហូរ៉េ, ពាស់ណា, សេដង៍, កាពួន, ហាឡ្រូ, ស្សៀង, មា៉នង (ម្នង) ។ល។
បញ្ចូលខាងខ្មែរកម្ពុជាក្រោមទាំងអស់ ។ មានពួកអ្នកដឹកនាំជាតិមា៉នងជាដើម មិនព្រមទទួលបញ្ជាពី ធីវ ឲ្យដេញពួកបាតុករ ខ្មែរកម្ពុជាក្រោមទេ គេបានឆ្លើយថា៖
" ប្រសិនបើយើង នៅជាមួយព្រះសង្ឃ បាតុករខ្មែរកម្ពុជាក្រោម គឺដើម្បីជួយអ្នកទាំងនោះ ឲ្យចូលក្នុងវិមាន ធីវ ហើយមិនមែនដេញ បាតុករទាំងនោះចេញទេ" ។
ជនជាតិ មា៉នង ដែលស្រឡាញ់ចូលចិត្ត ពួកប្រជាជនចិននៅក្នុងស្រុកនោះ បានរុញខ្មែរកម្ពុជាក្រោម ឲ្យយកអាវុធច្បាំង ។ ប៉ុន្តែខ្មែរកម្ពុជាក្រោម ជាអ្នកកាន់ព្រះពុទ្ធសាសនា ស្រឡាញ់

សន្តិភាពពុំយល់ព្រមធ្វើតាមទេ ដោយសង្ឃឹមថា ពួកយួនយៀកណាម និងមានគំនិតត្រឹមត្រូវ ប្រកបដោយវិចារណៈឡើងវិញ។

ចំណែកទាហានខ្មែរកម្ពុជាក្រោម ដែលច្រើនតែជាទាហាន ក្នុងកងទ័ពវៀតណាម ក៏ដូចជាក្នុងកងទ័ពអាមេរិកកាំងដែរ ហើយក៏ដោយសារ ទាហានខ្មែរកម្ពុជាក្រោមនេះ បានជាអាមេរិកកាំង, និងយួនបានឈ្នះចម្បាំងជាច្រើន ជាមួយយួនយៀកកុង ទាហានខ្មែរកម្ពុជាក្រោម មានលក្ខណៈស្លូតស្ងៀម អត់ធន ហើយមាន វិន័យច្បាស់លាស់ ចាប់តាំងពីបាតុកម្មតំបូង ។

ប៉ុន្តែត្រូវបារម្ភគិតថា ទាហានខ្មែរកម្ពុជាក្រោមទាំងនោះ មានចិត្តខ្ទោចផ្សាខ្លាំងណាស់ ដល់ព្រះសង្ឃដែលជាទីគោរពបូជារបស់គេ ។

យើងត្រូវដឹងថា ទាហានខ្មែរកម្ពុជាក្រោមទាំងនោះ ក៏ចង់បានលក្ខន្តិកៈ សម្រាប់ជនជាតិភាគតិចទាំងអស់ដែរ ។

បើគេគ្មានផ្តល់សិទ្ធសេរីភាព និងការបំរើជាវិជ្ជមាន ដល់ព្រះ

សង្ឃឲ្យបានរីកចំរើនទេ នោះគេគ្មានគំនិតណា និងសម្ចាប់ព្រះសង្ឃឡើយ ។

ម្យ៉ាងទៀតកងទ័ព វណសិរ្យតស៊ូកម្ពុជាក្រោម មាននៅគ្រប់កន្លែង ។

តើនិងមានអ្វីកើតឡើង នៅក្រោយដែលជនជាតិយួនមិនយល់ព្រម អនុម័ត្តលក្ខន្តិកៈនេះ ដល់ខ្មែរកម្ពុជាក្រោម ឲ្យបានសប្បាយពេញចិត្ត ?

តើការអំណត់ព្យាយាមខាំមាត់ របស់ខ្មែរកម្ពុជាក្រោមត្រូវបញ្ឈប់ឬ?

ប្រវត្តិសាស្ត្របានបង្ហាញនូវជោគវាសនា របស់ជនជាតិខ្មែរក្រោម ដែលជាបុព្វហេតុ នៃការខ្វល់ខ្វាយឥតស្រាកស្រាន្តរវាងប្រជាជាតិខ្មែរក្រោម និងការគំរាមកំហែងដល់សន្តិភាពពិភពលោក ។

- ★ នេះជាឱកាស ដែលជនជាតិយួន ត្រូវយល់អំពីយើង ។
- ★ នេះជាពេលវេលា ដែលសហរដ្ឋអាមេរិក ត្រូវធ្វើអ្វី

ដើម្បីឲ្យ បានសម្រេចហើយ ។

★ នេះជាឱកាសមួយ ដែលមហាអំណាចនាំមកនូវសន្តិភាព និងយុត្តិធម៌ ធ្វើអន្តរាគមន៍ដើម្បី ទប់ស្កាត់ មិនឲ្យមានភាព ចង្រៃអន្តរាយតទៅទៀត ។

★ នេះជាពេលវេលា ដែលអង្គការសហប្រជាជាតិ ត្រូវតែអនុវត្តនូវ ធម្មនុញ្ញរបស់ខ្លួន និងការប្រកាសជាសកលនៃសិទ្ធិមនុស្ស ដល់ខ្មែរកម្ពុជាក្រោម ចំនួន+១២លាន នាក់ ដែលធ្វើសំណូមពរ ឲ្យស្របទាំងអស់គ្នាហើយ ។

សូមរង់ចាំអាន អំពីការតស៊ូដ៏ស្វិតស្វាញរបស់ខ្មែរក្រោម

ដើម្បីរក្សាជាតិកំណើតជាតិខ្មែរ ! សាសនា !

និងទឹកដីខ្មែរជានិច្ច !